ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស.ប.ស.ខ

សមាគមបុគ្គលិកសិក្សាខ្មែរ

៤៧

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

# ទស្សនាវដ្ដី គ្រូបង្រៀន



លោកគ្រូភាសាខ្មែរ សេក ណាន និង លោកគ្រូគណិត លី ឡៃហេង

**ត្រីមាសទី៤ ឆ្នាំ ២០១៥**

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១២ ៦៣៨ ៨៨៩

អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា

* **គណៈកម្មការរៀបរៀងនិងនិពន្ធ**

- លោក ជ័យ សឈ្យនា
- លោក ថោង ប៊ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោក ស្វាយ ឋិត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ថាច់ ធីសារ៉ែន
- លោកស្រី ម៉ក់ ណាង
- លោក ឡៅ សុផន
- លោក អ៊ុំ ជា

សមាជិកសមាជិកា ស. ប. ស. ខ.

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ឹម
- លោកស្រី ប្រាក់ សូលីដា
- លោក ស៊ុង វ៉ាន់ថន
- លោក រ័ត្ន ហួត
- លោក ស្អួង សារុណា
- លោក ស៊ិន ស៊ឹម

## ភារីកុំព្យូទ័រ

លោក ហៃ វីរៈ

## ក្របខាងក្រៅ

- **ពីមុខ** : ឯកឧត្តមរដ្ឋមន្ត្រី បំពាក់មេដាយជូនគ្រូមានស្នាដៃ
- **ពីក្រោយ** : វិទីអូហ៊ីយ៉េ(បច្ចុប្បន្នវិថីព្រះអង្គអេង)


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| ២ | អភិវន្ទន៍អបអរសាទរ " ទិវាគ្រូបង្រៀន៥តុលា " | ២ |
| | **រាជកិច្ច** | |
| ៣ | ច្បាប់ស្តីពីការអប់រំ (តចប់) | ៣ |
| | **វប្បធម៌ទូទៅ** | |
| ៤ | ហេតុអ្វីបានជាគេធ្វើពិធីបុណ្យអុំទូក លយប្រទីប និងសំពះព្រះខែ | ៦ |
| ៥ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៧ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៦ | ឫកពា | ៩ |
| ៧ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ១១ |
| | **ការអប់រំនិងគរុកោសល្យ** | |
| ៨ | របៀប វិធីផ្ទាល់ខ្លួនរបស់គ្រូក្នុងការបង្រៀន (ត) | ១៣ |
| ៩ | អភិវឌ្ឍន៍របៀបធ្វើការជាក្រុម (តចប់) | ១៦ |
| ១០ | សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា (ត) | ១៧ |
| ១១ | ផ្តុំប្រធានចំណោទសារឡើងវិញ | ១៩ |
| | **វិទ្យាសាស្ត្រព័ត៌មានបច្ចេកវិទ្យា** | |
| ១២ | គេហទំព័រគ្រូ | ២២ |
| | **កំណាព្យនិងកម្សាន្ត** | |
| ១៣ | ម៉ែ (បទកាកគតិ) | ២៥ |
| ១៤ | ការងារកសិកររដូវវស្សា (បទពាក្យប្រាំពីរ) (តចប់) | ២៦ |
| | **វេទិការស្វែរិន** | |
| ១៥ | ពុទ្ធសាសនានៅប្រទេសកម្ពុជា (ត) | ២៨ |
| ១៦ | សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ (ត) | ៣០ |
| | **ព័ត៌មាន** | |
| ១៧ | ប្រព័ន្ធលេខក្នុងភាសាខ្មែរ | ៣២ |
| ១៨ | ចំណាប់អារម្មណ៍របស់លោក សេក ណន | ៣៤ |
| ១៩ | ចំណាប់អារម្មណ៍របស់លោក លី ឡៃហេង | ៣៥ |
| ២០ | ស្ថិតិសពពីខែឧសភា ដល់ខែវិច្ឆិកា ឆ្នាំ២០១៤ | ៣៧ |


## ទូរស័ព្ទផ្ទះគ្រូបង្រៀន

- ភ្នំពេញ : ០៨៩ ៦៨៤ ០៨១
- ព្រះសីហនុ : ០១២ ៦៥៩ ៥៦០
- សៀមរាប : ០១២ ៦៧៥ ៦៤០
- កំពង់ចាម : ០១១ ៧៤២ ២២៤
- ស្វាយរៀង : ០៩៧ ២ ៦៥៥ ៩៨៧
- ព្រៃវែង : ០១២ ៦៧១ ៦៤០
- កំពត : ០១២ ៨៥៦ ៧២២
- កែប : ០៩៧ ៨ ៧២១ ៨៨០
- តាកែវ : ០៩៧ ៩ ៧៦១ ៥៨៨
- រតនគិរី : ០៩៧ ៩ ០៤២ ៥៨៤
- ព្រះវិហារ : ០១២ ២១៨ ២៨១
- បាត់ដំបង : ០១២ ៦៧៣ ៦៦២
- ស្ទឹងត្រែង : ០១២ ៩៦៤ ៤៩៦

# វិចារណកថា

UNESCO បានកំណត់យកការអប់រំមានគុណភាព ការរក្សាការពារបេតិកភណ្ឌវប្បធម៌ ដែលរងគ្រោះថ្នាក់និងសេរីភាពនៃការសម្តែងមតិជាផ្នែកបំពេញបង្គ្រប់ សម្រាប់ឆ្លើយតបនឹងគោលនយោបាយប្រកបដោយប្រសិទ្ធភាពនិងចីរភាពនៃការខិតខំប្រឹងប្រែងកសាងសន្តិភាពក្នុងសតវត្សទី ២១ ។

UNESCOក៏បានបង្កើនការខិតខំប្រឹងប្រែងផងដែរក្នុងន័យគាំទ្របណ្តាប្រទេសដើម្បីពន្លឿនវឌ្ឍនភាពឈានទៅសម្រេចគោលដៅនៃការអភិវឌ្ឍសហសវត្សនិងផែនការថ្មីនៃការអភិវឌ្ឍពិភពលោកក្រោយឆ្នាំ២០១៥ ។

ចាប់ពីឆ្នាំ ២០០០មក បទពិសោធន៍បង្ហាញថា វឌ្ឍនភាពពុំអាចកើតមានទេ ប្រសិនបើការអភិវឌ្ឍមនុស្សគ្មានជាតុកណ្តាលនៃលក្ខណៈពិធម្មជាតិរបស់គេ ដូចជា វប្បធម៌ សមត្ថភាពច្នៃប្រឌិតបង្កើតថ្មី និងការអប់រំ។ ភាពប៉ិនប្រសប់ខាងច្នៃប្រឌិតឥតព្រំដែននេះ គឺជាគំនិតប្រាជ្ញាស្មារតីរបស់គេ (មនុស្ស) ។

ដូចនេះ ការអប់រំមានសារៈសំខាន់ណាស់ដែលសន្និសីទពិភពលោកអំពីការអប់រំសម្រាប់ទាំងអស់គ្នា និងរបាយការណ៍កម្រិតអន្តរជាតិផ្សេងៗបានបញ្ជាក់ច្បាស់ពីតួនាទីដឹកនាំមិនអាចខ្វះបាននៃ UNESCO ក្នុងការរៀបចំកសាងផែនការថ្មីក្រោយឆ្នាំ ២០១៥ ។ ផែនការនេះ កំណត់ពីចក្ខុវិស័យទូទៅនៃអនាគតរបស់ការអប់រំ ដែលសង្កត់លើគោលដៅរួម គឺ ការអប់រំដោយសមធម៌ មានគុណភាព និងការហ្វឹកហ្វឺនមុខរបរពីពេលនេះដល់ឆ្នាំ ២០៣០ ។ ក្របខ័ណ្ឌសកម្មភាពដែលនឹងពិភាក្សាសម្រេចនាឆ្នាំ ២០១៥ នៅ Incheon សាធារណរដ្ឋកូរ៉េ ប្រាកដនឹងដាក់ការអប់រំជាអាទិភាពទី១ ក្នុងផែនការថ្មីនៃការអភិវឌ្ឍ ដោយចីរភាពក្រោយឆ្នាំ ២០១៥ ។

UNESCO នឹងរៀបចំចាត់ចែងការប្រជុំពិភពលោក អំពីវប្បធម៌និងឧស្សាហកម្មវប្បធម៌នៅ Florence ប្រទេសអ៊ីតាលីនាខែតុលាឆ្នាំ ២០១៥ ដែលការប្រជុំនេះនឹងប្រកាសព័ត៌មានអំពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃភាពជាដៃគូអភិវឌ្ឍន៍ ទាក់ទងនឹងឧស្សាហកម្មវប្បធម៌ ដែលជាកម្លាំងចលករនៃការអភិវឌ្ឍដោយចីរភាពរវាងរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងផ្នែកឯកជន ។

សន្និសីទពិភពលោកអំពីការអប់រំដើម្បីអភិវឌ្ឍន៍ដោយចីរភាពដែលរៀបចំដោយ UNESCO នៅ Aichi-Nagoya ប្រទេសជប៉ុនបានជំរុញបញ្ចប់ផែនការ ១០ឆ្នាំ របស់ អ.ស.ប. អំពី «ការអប់រំដើម្បីអភិវឌ្ឍដោយចីរភាព ២០០៥-២០១៤» និងបានដាក់ចេញកម្មវិធីពិភពលោក ដែលមានគោលបំណងថ្មី ទិសដៅនិងយុទ្ធសាស្ត្រថ្មី ព្រមទាំងវិស័យការងារអាទិភាពសំខាន់ៗមួយចំនួនទៀត ។

ជារួមការអប់រំវប្បធម៌និងសេរីភាពនៃការបញ្ចេញមតិ ដែលជាកត្តាជំរុញមានលក្ខណៈសកលនៃការអភិវឌ្ឍធនធានមនុស្សនិងសមភាពយេនឌ័រ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ** បាននិងកំពុងបន្តអនុវត្តតាមរយៈគោលនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣យុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ប្រកបដោយផ្លែផ្កាវិជ្ជមាន ។

**គណៈកម្មាធិការកណ្តាល ស.ប.ស.ខ.**

# អភិវន្ទន៍អបអរសាទរ "ទិវាគ្រូបង្រៀន ៥ តុលា"

ឆ្នាំ២០១៥ ជាខួបលើកទី១៨ នៃថ្ងៃបង្កើត **ទិវាគ្រូបង្រៀនកម្ពុជា៥តុលា** តាមគំនិតផ្តើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងស្មារតីបំផុសប្រជាជាតិឲ្យមើលឃើញ ពីគុណូបការៈរបស់គ្រូបង្រៀន ដែលជាអ្នកមានចំណែកមិនអាចខ្វះបានក្នុងការកសាងធនធានមនុស្សគ្រប់វ័យ គ្រប់ភេទ ឲ្យក្លាយជាពលរដ្ឋល្អ ។ ដោយឡែកសម្រាប់ **ទិវាគ្រូបង្រៀនអន្តរជាតិ ៥តុលា** វិញ ឆ្នាំនេះ គឺជាខួបលើកទី៤៩ ។

ដូចយើងទាំងអស់គ្នាដឹងហើយថា ឆ្នាំ២០១៥នេះ គឺជាឆ្នាំបញ្ចប់កម្មវិធីអភិវឌ្ឍរបស់ពិភពលោក អំពី "ការអប់រំសម្រាប់ទាំងអស់គ្នា" ដែលគ្រប់រដ្ឋាភិបាល និងផ្នែកពាក់ព័ន្ធទាំងអស់រួមទាំងប្រទេសកម្ពុជាផងដែរ បានអនុវត្តប្រកបដោយការទទួលខុសត្រូវ អស់រយៈពេល១៥ឆ្នាំ និងបានឆ្លើយតបជាមូលដ្ឋានដល់តម្រូវការរៀនសូត្ររបស់កុមារា កុមារី យុវជន យុវនារី និងមនុស្សប្រុស ស្រី ។ ជាក់ស្តែងគោលដៅនៃការចូលរៀនជាសាកល នៅកំរិតបឋមសិក្សា មានការកើនឡើងគួរឲ្យកត់សម្គាល់ ។ ក៏ប៉ុន្តែ យើងឃើញមានមនុស្សរាប់រយលាននាក់ ក្នុងពិភពលោក ពិសេសស្ត្រី នៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ទាក់ទងនឹងការអាន ការសរសេរ និង ការគិតលេខនៅឡើយដែរ។

ទន្ទឹមនឹងនេះ ក្របខណ្ឌនៃការពិគ្រោះយោបល់ជាអន្តរជាតិ ដែលរៀបចំចាត់ចែងដោយអង្គការ UNESCO និងUNICEF លើការងារអប់រំក្នុងកម្មវិធីអភិវឌ្ឍ ក្រោយឆ្នាំ២០១៥ និងមានការចូលរួមពីអ្នកឯកទេសអប់រំប្រមាណ ៧សែននាក់នៃ ១៩៤ប្រទេស បានដាក់ចេញនូវរបាយការណ៍អង្កេត ដោយកំណត់គោលដៅជាអាទិ ការអប់រំ ទឹកស្អាត អនាម័យ និងសុខភាពសាធារណៈ និងសមភាពភេទ តែពុំបានគិតដល់មនុស្សងាយរងគ្រោះ និងមនុស្សដែលសង្គម មិនចាប់អារម្មណ៍ ។ ភាគច្រើននៃអ្នកឯកទេសអប់រំខាងលើ បានផ្តោតការយកចិត្តទុកដាក់លើការអប់រំមាន គុណភាព និង ការចូលរៀន១០០% នៃកុមារដល់វ័យសិក្សា ។ ឯគោលដៅអក្ខរកម្មមនុស្សចាស់វិញ គេចាត់ទុកជាអាទិភាពបន្ទាប់ ។ ទីបំផុត ក្របខណ្ឌនេះមិនអាចក្លាយជាគម្នាស់វិជ្ជមានដល់ការអប់រំកុមារ យុវជន និងមនុស្សចាស់ទាក់ទង នឹងចំណេះដឹង សមត្ថភាព និងតម្លៃនៃពលរដ្ឋល្អ ដើម្បីជីវភាពផ្ទាល់ខ្លួន សមភាពភេទ សង្គមសុខក្សេមក្សាន្ត និងសេដ្ឋកិច្ចរីកចំរើន ។

បច្ចុប្បន្ននេះ កំណើនប្រជាជនពិសេសប្រជាជនវ័យក្មេង ការប្រែប្រួលធាតុអាកាស វឌ្ឍនភាពសង្គម និងការរីវត្តវិសមភាពបានធ្វើឲ្យប៉ះពាល់ដល់តម្រូវការអប់រំ មានប្រសិទ្ធភាព គុណភាព និងសមធម៌នៃគ្រប់ប្រទេស។ ដូចនេះ ក្របខណ្ឌអប់រំដែលចុះសម្រុងនឹងសុខដុម គប្បីចាត់ចែងលើគោលការណ៍គ្មានការរើសអើង គ្មានវិសមភាព និងគប្បីចាត់ទុកជាសិទ្ធិ និងជាទ្រព្យផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ។ ក្របខណ្ឌនេះ ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធជាអាទិ រដ្ឋាភិបាល គ្រូបង្រៀន សិស្ស និស្សិត វិនិយោគិន សង្គមស៊ីវិល និងក្រុមជំនាញពាក់ព័ន្ធ។

ក្នុងន័យនេះ អគ្គលេខាធិការនៃ អ.ស.ប. បានស្នើជាគោលដៅអភិវឌ្ឍវិស័យអប់រំ ក្រោយឆ្នាំ២០១៥ថា ការអប់រំមានគុណភាព និងការហាត់រៀនមុខរបរវិជ្ជាជីវៈ ជាប្រចាំអស់មួយជីវិត ។ កម្មវិធីនេះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** តាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការ បាននិងកំពុងអនុវត្តយ៉ាងសកម្ម និងសង្ឃឹមថា គោលដៅដើម្បី គុណភាពអប់រំ និងសមត្ថភាពវិជ្ជាជីវៈ មានឯកទេស នឹងសម្រេចតាមការរំពឹងទុក ។

សមាគមបុគ្គលិកសិក្សាខ្មែរ ស.ប.ស.ខ. សូមយកឱកាសដ៏ប្រពៃនេះ ថ្លែងការកោតសរសើរដោយស្មោះ និងជូនពរស័ព្ទសាធុការចំពោះលោកគ្រូ អ្នកគ្រូទាំងអស់ដែលបានរួមចំណែកធ្វើឲ្យសម្រេច គោលដៅអភិវឌ្ឍ "ការអប់រំសម្រាប់ទាំងអស់គ្នា" និងបានខិតខំបង្ហាត់បង្រៀន សិស្ស និស្សិត ទាំងអស់ដោយទឹកចិត្តស្រឡាញ់ និងចង់ឲ្យពួកគេរៀនចេះចាំគ្រប់ៗគ្នា ។ នេះជាស្មារតីពិតប្រាកដរបស់គ្រូបង្រៀន ដោយគ្មានទាមទារអ្វី ក្រៅពីចង់ឮពួកគេនិយាយថា " ខ្ញុំជាកូនសិស្សលោកគ្រូ អ្នកគ្រូ " - " ខ្ញុំមានកិត្តិយសដូចសព្វថ្ងៃនេះ ដោយសារលោកគ្រូ អ្នកគ្រូ" តែប៉ុណ្ណោះ។

សូមឧទ្ទិសឲ្យគោលបំណង និងអត្ថន័យនៃទិវាគ្រូបង្រៀនកម្ពុជា ៥តុលា ព្រមទាំងឧបការៈនៃអ្នកផ្តើមគំនិតបង្កើតទិវានេះ ស្ថិតនៅក្នុងបេះដូងនៃប្រជាជនកម្ពុជាគ្រប់ៗរូបជារៀងរហូត ។

**គណៈកម្មាធិការកណ្តាល ស.ប.ស.ខ.**

# ច្បាប់ស្តីពីការអប់រំ (តចប់)

**គ្រឹះស្ថានសិក្សា :** សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាបណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬ សាកលវិទ្យាល័យ ឬ មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ។

**គ្រឹះស្ថានឧត្តមសិក្សា :** សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាដែលផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញឯកទេសកម្រិតក្រោយមធ្យមសិក្សា ។

**បំណិនជីវិត :** សំដៅដល់ចំណេះដឹងដែលផ្តោតលើសុខភាព ការបង្ការទប់ស្កាត់ អាហារូបត្ថម្ភ ការយល់ដឹងពីកិច្ចការពលរដ្ឋ និងបរិស្ថាន ជំនាញសង្គម និងជំនាញក្នុងការប្រាស្រ័យទាក់ទងភ្ជាប់របស់អ្នកសិក្សា ។

**បុគ្គលិកអប់រំ :** សំដៅដល់មន្ត្រី ដែលកំពុងបម្រើការក្នុងវិស័យអប់រំ និងបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ និងសាស្ត្រាចារ្យដែលបម្រើការនៅឧត្តមសិក្សា ។ បុគ្គលិកអប់រំរួមមានបុគ្គលិកបង្រៀន ឬ មិនបង្រៀនក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ឬ បុគ្គលិកបម្រើការក្នុងវិស័យអប់រំឯកជនគ្រប់លំដាប់ថ្នាក់ លើកលែងតែមន្ត្រីនយោបាយដែលកំពុងដឹកនាំវិស័យអប់រំក្នុងក្រសួងស្ថាប័នរដ្ឋ ។

**ភាសាអន្តរជាតិ :** សំដៅដល់ភាសាបរទេសទាំងឡាយណា ដែលត្រូវបានគេនិយមប្រើប្រាស់ច្រើនជាងគេលើឆាកអន្តរជាតិ ។

**វិទ្យាស្ថាន :** សំដៅដល់គ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់ការអប់រំ តាមរយៈមុខជំនាញសិក្សាមួយ ឬ ច្រើន ។

**គ្រឹះស្ថានសិក្សាសាធារណៈ :** សំដៅដល់ស្ថាប័នអប់រំដែលគ្រប់គ្រងដោយអាជ្ញាធរអប់រំសាធារណៈ ឬ ដោយភ្នាក់ងាររដ្ឋ ឬ ដោយក្រុមប្រឹក្សាភិបាល ឬ ក្រុមប្រឹក្សាសាលារៀនដែលមានសមាជិកភាពច្រើនត្រូវបានតែងតាំងដោយអាជ្ញាធរសាធារណៈ ឬ ត្រូវបានបោះឆ្នោតជ្រើសរើស ។

**គ្រឹះស្ថានសិក្សាឯកជន** : សំដៅដល់ស្ថាប័នអប់រំ ដែលគ្រប់គ្រងដោយបុគ្គលឯកជន ឬ ដោយក្រុមប្រឹក្សាភិបាលឯកជន ឬ ក្រុមប្រឹក្សាសាលារៀនឯកជន ។

**សាកលវិទ្យាល័យ**: សំដៅដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានបេសកកម្មផ្តល់ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ។ សាកលវិទ្យាល័យមានមហាវិទ្យាល័យច្រើនជាចំណុះដែលក្នុងនោះត្រូវមានមហាវិទ្យាល័យ ៣ ជាចាំបាច់គឺ មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រនិងភាសា មហាវិទ្យាល័យគណិតសាស្ត្រនិងវិទ្យាសាស្ត្រ និងមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងយ៉ាងតិចត្រូវមានមហាវិទ្យាល័យបន្ថែមពីរផ្សេងទៀត ។

**សិទ្ធិចន្លងនៃអាជ្ញាប័ណ្ណអប់រំ**: សំដៅដល់អ្នកទទួលសិទ្ធិពាក់ពន្ធ័លើផលប្រយោជន៍នៃអាជ្ញាប័ណ្ណអប់រំ តាមរយៈការផ្ទេរសិទ្ធិ ការលក់ ឬ ការស្នងមរតកជាដើម ។

**ស្ថាប័នអប់រំ** : សំដៅដល់ស្ថាប័នដែលមានគោលបំណងផ្តល់សេវាអប់រំ ។ ស្ថាប័នអប់រំមានស្ថាប័នអប់រំសាធារណៈ និងស្ថាប័នអប់រំឯកជន ។

**ស្ថាប័នអប់រំសាធារណៈ**: សំដៅដល់ស្ថាប័នអប់រំ ដែលគ្រប់គ្រងដោយអាជ្ញាធរអប់រំ សាធារ-ណៈ ឬ ក្រសួងស្ថាប័នរដ្ឋ ។

**ស្ថាប័នអប់រំឯកជន** : សំដៅដល់ស្ថាប័នអប់រំ ដែលដំណើរការគ្រប់គ្រងដោយបុគ្គល ឯកជន សមាគម ឬ អង្គការក្រៅរដ្ឋាភិបាល។

**ស្តង់ដារជាតិអប់រំ** : សំដៅដល់លក្ខណវិនិច្ឆ័យអប្បបរមាសម្រាប់វាយតម្លៃកម្រិតអប់រំនៃប្រព័ន្ធអប់រំ ។

**ស្តង់ដារជាតិបណ្តុះបណ្តាល** : សំដៅដល់លក្ខណវិនិច្ឆ័យអប្បបរមាសម្រាប់វាយតម្លៃកម្រិតនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**ស្តង់ដារជាតិសមត្ថភាព** : សំដៅដល់លក្ខណវិនិច្ឆ័យអប្បបរមា សម្រាប់វាយតម្លៃសមត្ថភាពរបស់សិក្ខាកាមដែលទទួលបានពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

**អាជ្ញាប័ណ្ណអប់រំ** : សំដៅដល់លិខិតអនុញ្ញាត ដែលចេញដោយអាជ្ញាធរអប់រំសាធារណៈដើម្បីផ្តល់សិទ្ធិឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាអ្នកគ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិនៃគ្រឹះស្ថានសិក្សាអាចដំណើរការសកម្មភាពអប់រំរបស់ខ្លួនដោយស្របច្បាប់បាន ។

**អ្នកកាន់អាជ្ញាប័ណ្ណអប់រំ** : សំដៅដល់បុគ្គលដែលទទួលបានសិទ្ធិអនុញ្ញាតឱ្យដំណើរការសកម្មភាពអប់រំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចស្របតាមនីតិវិធីច្បាប់ជាធរមាន។

**អ្នកសិក្សាពិការ** : សំដៅដល់អ្នកសិក្សាពិការ ដែលទទួលបានការសម្របសម្រួលក្នុងការអប់រំ ។ អ្នកសិក្សាពិការទាំងនោះរួមមានពិការ ជើងម្ខាង ឬ ទាំងសងខាង ថ្លង់ គរ ឬ ពិការភ្នែកទាំងសងខាង និងពិការផ្នែកស្មារតី ។

**អាហារូបករណ៍**: សំដៅដល់ប្រាក់ដែលផ្តល់ឱ្យអ្នកសិក្សា ដើម្បីទំនុកបម្រុងការសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ ។

**ឧបត្ថម្ភធន** : សំដៅដល់ប្រាក់ឧបត្ថម្ភជួយទំនុកបម្រុងផ្នែកណាមួយដែលជាកង្វះខាតខាងជីវភាពរបស់អ្នកសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ ។

**ឥណទានសិក្សា** : សំដៅដល់ប្រាក់កម្ចី ដែលរដ្ឋអនុញ្ញាតឱ្យអ្នកសិក្សាខ្ចី ដើម្បីបំពេញតម្រូវការក្នុងផ្នែកណាមួយដែលខ្វះខាតក្នុងរយៈពេលសិក្សា ហើយប្រាក់ដែលខ្ចីនេះ ត្រូវសងជូនរដ្ឋវិញក្នុងពេលកំណត់ណាមួយ ។

( ចប់ )

### រំលឹកជាតិ

- ហៃអស់កុមារ នាំគ្នាសិក្សា កុំថាប្រុសស្រី
  គឺអ្នកនេះហើយ ដែលត្រូវឃ្មាតខ្មី ការពារទឹកដី
  ទៅអនាគត ។
- គួរញាំងប្រាសាទ ដែលរចនាស្អាត លើផ្ទាំងសំពត់
  គឺអង្គទង់ជាតិ ត្រូវតែផ្គង់ផ្គត់ កុំឲ្យរលត់
  ពីផែនទីលោក ។

ម៉ែន ទន់

(មេសូត្រសំរាំង ១៩៥៣)




# ហេតុអ្វីបានជាគេធ្វើពិធីបុណ្យអុំទូក លយប្រទីប និងសំពះព្រះខែ

រៀងរាល់ឆ្នាំ នៅថ្ងៃ ១៤កើត ១៥កើត និង ១រោច ខែកត្តិក គេប្រារព្ធព្រះរាជពិធីបីគឺ ព្រះរាជពិធីអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ នៅព្រះរាជដំណាក់ផែខាងមុខព្រះបរមរាជវាំង ។ គេធ្វើពិធីទាំងបីនេះ ពីព្រោះគេគោរពប្រពៃណីដែលព្រះរាជាសម័យបុរាណបានធ្លាប់ធ្វើរៀងមក ។ តាមសៀវភៅព្រះរាជពិធីទ្វាទសមាស ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យបានសរសេរថា តាមសៀវភៅនិងឯកសារទាំងឡាយគេអាចសន្និដ្ឋាន ប្រទេសកម្ពុជាសម័យបុរាណជាប្រទេសមានកងទ័ពជើងទឹកខ្លាំងពូកែនិងមានពិធីហ្វឹកហ្វឺន ពិធីសមយុទ្ធនៃកងទ័ពនេះ ជាប្រពៃណីរាល់ឆ្នាំ ។ ព្រោះហេតុនោះ បានជាគេធ្វើព្រះរាជពិធីអុំទូកនេះ គឺជាប់មកពីព្រះរាជពិធីសមយុទ្ធនៃកងទ័ពជើងទឹកក្នុងសម័យបុរាណនោះឯង ។

ការធ្វើពិធីបណ្ដែតប្រទីបហៅថា លយប្រទីប ជាការបូជាចំពោះព្រះចង្កូមកែវនៅពិភពនាគ ដោយពួកពុទ្ធសាសនិកជនជឿថា ជាកុសលដ៏ធំ ដែលអាចផ្ដល់សេចក្ដីសុខចម្រើនដល់អ្នកធ្វើ ។

ចំណែកខាងប្រភពនៃព្រះរាជពិធីសំពះព្រះខែនោះ លោកបានសរសេរទុកក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាសភាគទី៣ ដូចមានសេចក្ដីជាគោលដែលខ្ញុំស្រង់មកចារឹកក្នុងទីនេះ ៖

## ប្រភពនៃព្រះរាជពិធីសំពះព្រះខែ

ក្នុងគម្ពីរបរមត្ថទីបនីអដ្ឋកថាចរិយាបិដកមានសម្ដែងសេចក្ដីថា កាលពីដើមព្រះពោធិសត្វទ្រង់ឧប្បត្តិកជាសត្វទន្សាយ។ នៅថ្ងៃពេញបូណ៌មីមួយទន្សាយនោះអធិដ្ឋានឧបោសថសីលឧទ្ទិសសាច់របស់ខ្លួនឲ្យជាទានបារមីដើម្បីឧបនិស្ស័យសម្រេចនូវពោធិញ្ញាណក្នុងអនាគតកាល ។ កាលនោះព្រះអមរិន្ទ្រពិនទេវតាបានជ្រាបនូវការនោះ ហើយក៏ប្រែកាឡាខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់ចូលមកសុំសាច់ទន្សាយនោះជាអាហារ ។ ទន្សាយពោធិសត្វបានបង្គាប់ឲ្យព្រាហ្មណ៍នោះបង្កាត់ភ្លើង ដើម្បីដុតព្រះអង្គ ។ លុះព្រាហ្មណ៍បង្កាត់ភ្លើងហើយទន្សាយក៏លោតទៅក្នុងភ្លើង តែភ្លើងឥតឆេះឡើយ ។ ព្រះឥន្ទ្រក៏ស្ទុះពបីទន្សាយទៅដល់ព្រះចន្ទ ហើយយកម្នាងសិលាគូររូបទន្សាយនៅមណ្ឌលព្រះចន្ទអធិដ្ឋានឲ្យជាប់នៅរហូតដល់ទីបំផុតកប្ប ។ ដោយអានុភាពនៃបារមីព្រះអង្គ ដែលព្រះឥន្ទ្រទ្រង់ជួយឧបត្ថម្ភផង រូបទន្សាយក៏ប្រាកដចន្ទមណ្ឌលដរាបដល់សព្វថ្ងៃ ។

ដោយជំនឿដូច្នេះហើយ បានជានៅវេលារាត្រីនៃថ្ងៃពេញបូណ៌មីខែកត្តិករៀងរាល់ឆ្នាំ គេតែងយកចំណីចំណុកមាន អំបុក ចេកទុំជាដើម អកបូជាព្រះចន្ទ ហៅថាពិធីអកអំបុក ឬសំពះព្រះខែរៀងមក ។

**លោក ចែម ផាន**

អធិការបឋមសិក្សា-សាស្ត្រាចារ្យប្រវត្តិវិទ្យា-បរិញ្ញាបត្រគ្រប់គ្រង

# ប្រវត្តិនៃការអប់រំ ក្នុងពិភពលោក(ត)

## ច. ការអប់រំដែលទាក់ទងដល់តួនាទីសង្គម

ក្នុងការរៀបចំវណ្ណៈ បុគ្គលម្នាក់ៗនៅក្នុងរដ្ឋ គួរទទួលបានការអប់រំដែលសមរម្យទៅតាមតួនាទីសង្គមរបស់គេ ៖

១. អធិរាជទស្សនវិជ្ជា ដែលត្រូវបានអប់រំសម្រាប់ភាពជាអ្នកដឹកនាំ ក៏ទទួលខុសត្រូវផងដែរសម្រាប់កំណត់អត្តសញ្ញាណអ្នកដែលមានសមត្ថភាពខាងបញ្ញា ទៅតាមមនុស្សជំនាន់ក្រោយ ហើយរៀបចំឲ្យគេទៅតាមតួនាទី ជោគវាសនានាពេលខាងមុខ ។

២. វណ្ណៈទី២ ដែលជាអ្នកចម្បាំង ជាអ្នកក្លាហានជាជាងអ្នកមានប្រាជ្ញា គួរតែត្រូវបានបណ្តុះបណ្តាលឲ្យការពារសាធារណរដ្ឋ ហើយនិងទទួលបទបញ្ជាពីអធិរាជទស្សនវិជ្ជា ។

៣. វណ្ណៈទី៣ និងជាវណ្ណៈធំជាងគេបំផុត គឺពួកកសិករ គួរត្រូវបានបណ្តុះបណ្តាលជាកសិករនិងសិប្បករ ។

ដោយមានការអប់រំមួយសម្រាប់ក្រុមនីមួយៗ រដ្ឋបានត្រៀមរៀបចំសមាជិករបស់ខ្លួនសម្រាប់មុខងារដ៏សមរម្យរបស់គេ ដែលជាបន្តបន្ទាប់បានរួមចំណែកដល់ភាពចុះសម្រុងគ្នាក្នុងសហគមន៍និងអនុវត្តន៍មុខងារទៅតាមសមត្ថភាព ។ ការរិះគន់ក្នុងសម័យទំនើបសព្វថ្ងៃនៃការរៀបចំសិស្សនៅក្នុងសាលារៀនអះអាងថាឧបករណ៍សម្រាប់បិទបាំង ពិតជាមានបំណងបង្កើតឡើងវិញនូវស្ថានភាពវណ្ណៈដែលមានរួចហើយ ជាជាងលើកទឹកចិត្តចលនាក្នុងចំណោមវណ្ណៈសង្គមទាំងឡាយ ។

## ឆ. ការអប់រំស្ត្រី

មិនដូចពួកអាថែន ប្លាតុងជឿជាក់ថាស្ត្រីគួរតែមានអភ័យឯកសិទ្ធិដូចគ្នា និងការទទួលខុសត្រូវដែលបានអនុញ្ញាតពីបុរស[1] ។ ស្ត្រីផងដែរបានធ្លាក់ទៅក្នុងវណ្ណៈ៣ ដែលប្លាតុងបានដាក់ចំពោះមនុស្ស ។ ស្ត្រីដែលមានឥទ្ធិពល ពុទ្ធិកម្រិតខ្ពស់ អាចក្លាយជាសមាជិកនៃវរជនខាងទស្សនវិជ្ជាដែលកំពុងតែគ្រប់គ្រង ។ អ្នកផ្សេងទៀតដែលជាបញ្ញាជនជាន់ទាបជាង គួររៀបចំឲ្យមានឋានៈទាបជាង ។ ស្ត្រីគួរទទួលបានការអប់រំ ឬការបណ្តុះបណ្តាលដែលសមរម្យទៅនឹងសមត្ថភាព និងមុខរបរដែលបានកំណត់ឲ្យដូចជាបុរសផងដែរ ។

## ជ. កន្លែងមើលថែទាំទារកដែលរៀបចំដោយរដ្ឋ

កម្មវិធីសិក្សារបស់ប្លាតុង សមស្របទៅនឹងវត្ថុបំណងអប់រំទៅតាមឋានានុក្រម ជាជាងទៅតាមសមត្ថភាពសង្គម ។ ដោយភ័យខ្លាចឪពុកម្តាយបន្តមត៌កភាពល្ងង់ខ្លៅ និងបុរេវិនិច្ឆ័យទៅឲ្យកូន ប្លាតុងចង់ឲ្យកុមារ

---

[1] *Robert S. Brumbaugh, Plato's Ideal Curriculum and Contemporary Philosophy of Education, Educational Theory (Spring 1987), pp.169-177.*

មានការចិញ្ចឹមដោយអ្នកជំនាញខាងការមើលថែទាំកុមារ ។ កុមារដែលត្រូវបានបំបែកចេញពីឪពុកម្ដាយនោះ គួរត្រូវរស់នៅក្នុងកន្លែងមើលថែទាំកុមាររបស់រដ្ឋ ដូច្នេះហើយ កុមារទទួលបានទម្លាប់ល្អនិងវិសុទ្ធកម្មភាពអាក្រក់ចេញ ។

### *ឈ. កម្មវិធីសិក្សាជាមូលដ្ឋានរបស់ប្លាតុង*

ពីអាយុ ៦ឆ្នាំ ដល់ ១៦ឆ្នាំ កុមារគួររៀននៅសាលា ដែលជាកន្លែងដែលគេត្រូវសិក្សាតន្ត្រីនិងកីឡាកាយសម្ព័ន្ធ ។ តន្ត្រី តាមនិយមន័យរបស់ប្លាតុង គឺជាមុខវិជ្ជាទូលំទូលាយ ដែលត្រូវបានរាប់បញ្ចូលទាំងការអាន ការសរសេរ អក្សរសិល្ប៍ នព្វន្តសាស្ត្រ ការច្រៀងជាក្រុម និងការរាំ ។

ក្រោយពេលចេះអាននិងសរសេរស្ទាត់រួចហើយ សិស្សគួរនឹងអានអក្សរសិល្ប៍ក្រិច និងឡាតាំង ។ ប្លាតុង បានចាត់ទុកអក្សរសិល្ប៍ជាកម្លាំងដ៏មានឥទ្ធិពលក្នុងការបង្កើតអត្តចរិត និងជឿជាក់ថា កុមារគួរតែអានកំណាព្យនិងរឿងដែលត្រូវយកជាគំរូភាពពិត ស្ដាប់បង្គាប់អាជ្ញាធរ សេចក្ដីក្លាហាន និងការគ្រប់គ្រងចិត្តរំភើប ។

ក្រោយពេលដែលទទួលបានមូលដ្ឋាននព្វន្តសាស្ត្រច្បាស់លាស់ហើយ សិស្សនឹងអនុវត្តដោយខ្លួនគេទៅនឹងធរណីមាត្រសាស្ត្រ និងតារាវិទ្យា ។

កីឡាកាយសម្ព័ន្ធដែលមានមុខងារខាងលំហាត់ប្រាណ មានប្រយោជន៍សម្រាប់ការហាត់ទ័ព ដូចជាការចាក់សាប ការបាញ់ធ្នូ ការគប់លំពែង និងការជិះសេះ គឺត្រូវបានចាត់ទុកជារឿងសំខាន់បំផុតសម្រាប់ការកសាងអត្តចរិតនិងការអភិវឌ្ឍខាងរាងកាយ ។ ប្លាតុង ក៏បានរាប់បញ្ចូលក្បួនច្បាប់នៃការតមអាហារនិងអនាម័យនៅក្នុងកម្មវិធីសិក្សារបស់គាត់ ។

### *ញ. ការអប់រំនៅឧត្ដមសិក្សា*

ពីអាយុ ១៨ឆ្នាំ ដល់ ២០ឆ្នាំ សិស្សនឹងបន្តការហ្វឹកហាត់យោធានិងរាងកាយច្រើនថែមទៀត ។ នៅអាយុ ២០ឆ្នាំ អធិរាជទស្សនវិជ្ជានាពេលអនាគតនឹងត្រូវបានជ្រើសរើសសម្រាប់រៀននៅឧត្ដមសិក្សា ១០ឆ្នាំបន្ថែមទៀតខាងគណិតវិទ្យា ធរណីមាត្រសាស្ត្រ តារាសាស្ត្រ តន្ត្រី និងវិទ្យាសាស្ត្រ ។ នៅអាយុ ៣០ឆ្នាំ អ្នកមានសមត្ថភាពខាងបញ្ញាទាបក្នុងចំណោមក្រុមនេះ នឹងក្លាយជាមន្ត្រីរាជការ (Civil Servants) ។ រីឯអ្នកដែលមានសមត្ថភាពបញ្ញាខ្ពស់បំផុត នឹងបន្តការសិក្សាទស្សនវិជ្ជាជាន់ខ្ពស់ជាងនេះទៀតផ្នែកបរមត្ថវិទ្យា ការស្រាវជ្រាវរកគោលការណ៍ដែលបានពន្យល់តថភាពកម្រិតខ្ពស់បំផុត ។ នៅពេលដែលការសិក្សារបស់គេត្រូវបានបញ្ចប់ អធិរាជទស្សនវិជ្ជានឹងចាប់ផ្ដើមដឹកនាំកិច្ចការនយោបាយនិងយោធារបស់រដ្ឋ ។នៅអាយុ ៥០ឆ្នាំ អធិរាជទស្សនវិជ្ជានឹងក្លាយជារដ្ឋបុរសដែលមានវ័យចំណាស់ ។

(នៅមានត)

**អនុបណ្ឌិត សូ សុធីរ**



# ចិត្តវិទ្យាអប់រំ

## ឫកពា

### ១. តើឫកពាជាអ្វី ?

ឫកពា គឺជាលក្ខណៈចិត្តនៃបុគ្គលិកលក្ខណៈដែលសម្ដែងចេញជាលក្ខណៈដោយឡែកនៃអាកប្បកិរិយា និងសកម្មភាពរបស់បុគ្គល ។

***ឧទាហរណ៍*** : ក្នុងជីវភាពរស់នៅរាល់ថ្ងៃ គេអាចធ្វើការសង្កេតចិត្តគំនិតរបស់អ្នកនៅជុំវិញ ឬអ្នកជិតខាងដោយផ្អែកលើលក្ខណៈពិសេសៗ ដែលសម្ដែងចេញតាមរយៈសកម្មភាពចិត្តរបស់មនុស្សនោះ ។

ឆ្លងតាមការសង្កេតនេះ គេបានកត់សម្គាល់ឃើញថា មនុស្សខ្លះមានអត្តចរិតដូចគ្នា ប៉ុន្តែការសម្ដែងចេញមកក្រៅមានសភាពខុសគ្នា ។ នេះបណ្ដាលមកពីគេមានឫកពាខុសគ្នា ។

***ឧទាហរណ៍*** : សិស្ស " ក " និង " ខ " មានអត្តចរិតស្រឡាញ់ការងារពលកម្មដូចគ្នា ។ ប៉ុន្តែសិស្ស "ក" បំពេញការងារដោយរហ័សរហួន រីឯសិស្ស " ខ " វិញធ្វើការយឺត តែស្អិតស្អេរទៀងទាត់ ។ ទីបញ្ចប់សិស្សទាំងពីរនេះ អាចបំពេញការងារបានចប់សព្វគ្រប់ដូចគ្នា ។

***ឧទាហរណ៍*** : ក្នុងល្បែងគេសង្កេតឃើញកុមារខ្លះមានសកម្មភាពខ្លាំង ខ្លះមានភាពនឹងនរ ខ្លះរ៉ូងរ៉ាំង ខ្លះស្វាហាប់ ខ្លះទៀតទុយមុយកំសាក...ទាំងនេះបណ្ដាលមកពីឫកពាដែរ ។

តាមឧទាហរណ៍រួចមកហើយនេះ យើងឃើញថាបុគ្គលនីមួយៗមានអាកប្បកិរិយាដោយឡែកពីគ្នា មានរបៀបធ្វើការងារដោយឡែកពីគ្នាដែរ ។ លក្ខណៈ ឬចំណុចដោយឡែកពីគ្នាទាំងនេះ ជាឫកពាផ្ទាល់នៃបុគ្គលនីមួយៗ ហើយបុគ្គលម្នាក់ៗខុសប្លែកពីបុគ្គលដទៃទៀត ។ ដូចនេះលក្ខណៈដោយឡែកទាំងនេះដែលមាននៅក្នុងអាកប្បកិរិយា និងក្នុងសកម្មភាព បង្កើតបានជាឫកពានៃបុគ្គលម្នាក់ៗ ។

ដើម្បីយល់ឲ្យបានច្បាស់លាស់អំពីឫកពារបស់មនុស្ស គេគប្បីសិក្សាស្វែងយល់ឲ្យបានហ្មត់ចត់ទៅលើកម្លាំង និងភាពវាងវៃនៃដំណើរការរបស់សរសៃប្រសាទ ព្រោះសរីរវិទ្យាស្ដីពីសរសៃប្រសាទ ជួយឲ្យយើងអាចសិក្សាស្រាវជ្រាវពីឫកពារបស់មនុស្សម្នាក់ៗបាន ។

### ២. ការពន្យល់អំពីឫកពា

តាំងពីបុរាណសម័យ លោក អ៊ីប៉ូក្រាត (៤៦០-៣៥៦ មុន គ.ស.) ដែលជាគ្រូពេទ្យដ៏ល្បីល្បាញនៃប្រទេសក្រិចសម័យបុរាណ បានធ្វើការបែងចែកមនុស្សជាតិជាបួនប្រភេទ ដោយពន្យល់ពីភាពខុសគ្នានៃឫកពា តាមវត្តមាននៃវត្ថុរាវបួនយ៉ាងខុសៗគ្នានៅក្នុងសព៌ាង្គកាយ ។ វត្ថុរាវបួនយ៉ាងនោះគឺ **ឈាម អ៊ុយម័រអាបោធាតុ ឬធាតុទឹកក្នុងខ្លួន ទឹកប្រមាត់លឿង និងទឹកប្រមាត់ខ្មៅ** ។ លក្ខណៈទាំងនេះកំណត់ឫកពា ៤ប្រភេទ ដូចតទៅ ៖

**ប្រភេទទី ១ :** ប្រភេទឈាមរាវមានឫកពាចិត្តមុតចំពោះអ្នកដែលមានឈាមច្រើន ។ គឺជា

ប្រភេទឫកពាសកម្ម ឬក្លៀវក្លា ។

**ប្រភេទទី ២** : អ៊ុយម័រ អាបោធាតុ ឬធាតុទឹកក្នុងខ្លួនមានឫកពាចិត្តរឹងប៉ឹង ។ នេះជាប្រភេទមនុស្សមានឫកពានឹងនរមិនងាយច្រឡោត ។

**ប្រភេទទី ៣** : ទឹកប្រមាត់លឿងច្រើននៅក្នុងថ្លើម មានឫកពាកាច ចិត្តស្រាល ។ គឺជាប្រភេទឫកពាឆាប់ញោច ឆាប់ច្រឡោត ឆេវឆាវ ។

**ប្រភេទទី ៤** : ទឹកប្រមាត់ខ្មៅ ច្រើនមានឫកពាព្រួយច្រើន ។ គឺជាប្រភេទឫកពាកើតទុក្ខ ចូលចិត្តនៅម្នាក់ឯងហើយមានកង្វល់ច្រើន ។

ក្រោយមកបាតុភូតនេះត្រូវបានលោក ប៉ាវឡូវ ពន្យល់ភាពខុសគ្នានៃឫកពាតាមប្រភេទនៃសកម្មភាពសរសៃប្រសាទ ។ ក្នុងសកម្មភាពសរសៃប្រសាទមានលំនាំពីរ គឺ រំញោច និងការទប់ ។ លំនាំទាំងពីរនេះអាចបណ្តាលឲ្យសកម្មភាពសរសៃប្រសាទខ្លាំង ឬខ្សោយ " មានលំនឹង ឬគ្មានលំនឹង " រហ័ស ឬមិនរហ័ស ។ ឫកពា គឺជាការសម្តែងចេញរបស់សកម្មភាពសរសៃប្រសាទ ។ ផ្អែកលើលក្ខណៈទាំងនេះហើយដែលលោក ប៉ាវឡូវ បានកំណត់ប្រភេទទាំងបួនរបស់ឫកពាដូចតទៅ ៖

**ប្រភេទទី ១** : សកម្មភាពសរសៃប្រសាទខ្លាំងមានលំនឹងរហ័ស ប្រភេទឫកពាសកម្ម ចិត្តមុត ឬឈាមពារ ។ មនុស្សដែលមានឫកពាប្រភេទនេះ ជាមនុស្សដែលឆាប់យល់ដឹង ឆាប់មានសញ្ចេតនារីករាយ រាក់ទាក់ក្លៀវក្លា គឺជាមនុស្សដែលឆាប់សម្របខ្លួនទៅនឹងមជ្ឈដ្ឋានថ្មី ។

***ឧទាហរណ៍ :*** សិស្សដែលមានឫកពាប្រភេទទី ១ ជាសិស្សដែលមានទឹកមុខរីករាយ រហ័សរហួន ឆាប់សម្របខ្លួនបានទៅនឹងវិន័យសាលា ឆាប់ធ្វើឲ្យគ្រូស្រឡាញ់ មិត្តភក្តិឆាប់រាប់អាន ឆាប់យល់មេរៀន ចូលចិត្តមើលមេរៀនថ្មីជាងមេរៀនចាស់ រៀនសាឡើងវិញ ។ សិស្សរបៀបនេះ មានតម្រូវការមួយចាំបាច់ គឺសកម្មភាពថ្មីៗចំពោះគេ ។

**ប្រភេទទី ២** : សកម្មភាពសរសៃប្រសាទខ្លាំង មានលំនឹង តែមិនរហ័ស ប្រភេទឫកពានឹងនរ ចិត្តរឹងប៉ឹង ។ មនុស្សឫកពាប្រភេទទី ២នេះ ជាមនុស្សស្ងប់ស្ងៀម ប្រុងប្រយ័ត្ន ស្ថិតស្ថេរ មានលំនឹងមិនតក់ក្រហល់មុននឹងធ្វើកិច្ចការអ្វីមួយ គេគិតពិចារណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ ដូចសុភាសិតមួយពោលថា " មុននឹងនិយាយត្រូវបង្វិលអណ្តាតប្រាំពីរដងសិន " ។ ប៉ុន្តែគេមានគុណវិបត្តិខ្លះដូចជា មានភាពយឺត មិនសូវក្លៀវក្លា លំបាកក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលនៃមជ្ឈដ្ឋានជុំវិញ ពិបាកនឹងទម្លាប់ខ្លួនក្នុងសហគមន៍ថ្មី ។

***ឧទាហរណ៍ :*** សិស្សដែលមានឫកពាប្រភេទទី ២នេះ ជាសិស្សព្យាយាម ស្ងប់ស្ងៀម ។ គេពិបាកនឹងចុះចំណោមមិត្តភក្តិ ។ គេហាក់ដូចជាខ្លាចគ្រូ ប៉ុន្តែនៅពេលណាដែលគេស្រឡាញ់គ្រូវិញ សញ្ចេតនានោះមិនងាយនឹងលុបបាត់ទៅវិញទេ ។ ក្នុងការរៀនក៏ដូច្នេះដែរ ការប្តូរពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀតក៏មានការលំបាក ដូចជាបន្ទាប់ពីគេសិក្សាមុខវិជ្ជាគណិតវិទ្យា ហើយឲ្យគេប្តូរទៅសិក្សាអក្សរសិល្ប៍វិញ ក្នុងករណីនេះសិស្សប្រភេទនេះប្តូរដោយពិបាក ។

(នៅមានត)

**លោក ជ័យ សយ្យនា**

ដកស្រង់ចេញពីឯកសាររបស់នាយកដ្ឋានបណ្តុះបណ្តាលឆ្នាំ ២០១០

# មាតាបិតា ពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត)

ប្រសិនបើអំពើនេះកើតលើរូបអ្នកវិញ តើអ្នកនឹងយល់ថាដូចម្ដេច ឬទាមទារឲ្យប្រព្រឹត្តជាទម្ងន់លើសនេះទៀត ឬក៏ទូញទ្រហោយំស្រែកអង្វរ ? អ្នកមានរន្ធត់ចិត្តឬទេ នៅពេលដែលឃើញដៃកូនដ៏តូចស្រទ្បន់ទាំងទ្វេខំរងស្កាត់រំពាត់និងខំខ្ទប់សាច់ខ្លួនដ៏ខ្ចីផង ពត់ពេនអែនអន តាមសន្ទុះចង្វាក់រំពាត់របស់លោកឪពុក ឬអ្នកម្ដាយវាយវាត់គ្មានត្រាប្រណី ព្រមទាំងសម្លុតសន្ធាប់គំរាមមិនឲ្យស្រែកយំ កុំឲ្យយំ ! ឈប់យំភ្លាម !...។ សំពះផង យំផង ខ្លួនញ័រចំប្រប់ ទូញអង្វរសុំការអាណិត « *ពុកម៉ែអាណិតខ្ញុំផង... ឈប់វ៉ៃខ្ញុំ... យាយតាអើយជួយខ្ញុំផង ! អូយឈឺណាស់ពុកអើយ ! ម៉ែអើយ !...*» ។ ចម្លើយដែលឆ្លើយថា **ខ្ញុំរាងចាលហើយ ! ខ្ញុំខ្លាចហើយ !** ... ចម្លើយនេះពិតជាផុសចេញពីបេះដូងស្មោះត្រង់ឬទេ ? មិនពិតទេ ! ជាចម្លើយដើម្បីដោះទាល់មួយគ្រាប៉ុណ្ណោះ ។ តើលោកអ្នកទទួលបានផលពិតឬទេ ? លទ្ធផលគឺមិនពិតទេ ។ បើសិនជាពិតហេតុម្ដេចបានជាលោកអ្នកពោលថា : អានេះរឹងណាស់... ឪវាវ៉ៃនឹងខ្សែភ្លើងក៏មិនរាងចាលដែរ... ។

នៅពេលនេះ កូនចេះកុហកបោកប្រាស់ហើយ ហើយក៏ព្រោះតែនរណា ? នៅក្នុងភាពរងទារុណដូចគ្នា យើងក៏បានសង្កេតឃើញមានពេលខ្លះកូនមិនស្រែកទ្រហោទូញយំ តែស្ងៀស្រក់ទឹកភ្នែកដក់ដាមផ្ទៃមុខកែវភ្នែកក្រហមល្អក់ គ្មានស្ដីមួយម៉ាត់ តើក្នុងចិត្តពុះពោរដោយការឈឺចាប់ប៉ុណ្ណា តើអ្នកដឹងថា ក្នុងចិត្តកូនបានគិតអ្វីខ្លះ... គុំកួន ឬក៏... ? លោកអ្នកនៅតែមិនដឹង និងមិនទទួលបានការពិតរហូត ។ ថែមពីលើនេះទៀត កូនលោកអ្នកនឹងមានស្ថានភាពឥរិយាបថយ៉ាងណា ? គួរឲ្យសង្វេគពន់ពេកក្រៃ ចំពោះបុត្រថ្លៃដែលមានម្ដាយឪពុកបែបនេះ ! ។

តើលោកអ្នកនៅប្រើអំពើហិង្សា ទាំងពាក្យសម្ដីនិងទាំងទណ្ឌកម្មលើរាងកាយ ក្រោយពីវាយដំរួចហើយ ភាគច្រើនលើសលប់ កូនលោកអ្នកនឹងអាចជាមនុស្សឆេវឆាវ ។ ពាក្យសម្ដីទូន្មាន ក្លាយជាឥតប្រយោជន៍ ព្រោះកូនលែងយល់នូវអ្វីទាំងអស់ ។ ជួនកាលអាចនឹងមានប្រតិកម្មតបយ៉ាងអាម៉ាស់ទៀតផងក៏សឹងមាន ឬក៏ម៉ក់ៗ តុះតុញ អាប់ប្រាជ្ញា មិនសូវនិយាយស្ដីខុសពីមុន ដោះស្រាយហេតុការណ៍អ្វីៗដោយកម្លាំងបាយ ។ ប្រើវិធីតែមួយគត់ គឺបំពានដើម្បីយកឈ្នះតែមួយមុខគត់ ដូចទង្វើរបស់អ្នកទៅលើកូនអ្នកដូច្នោះដែរ ...។ នៅមានឥរិយាបថអសកម្មរបស់កូនជាច្រើនទៀត។នោះមានតែការទទួលស្គាល់ការពិតរបស់គ្រួសារលោកអ្នកដែលធ្លាប់ប្រព្រឹត្ត ទើបអាចដឹងច្បាស់អំពីផលវិបាកនេះ ។

ទណ្ឌកម្មលើកទី ១ ការវាយដំទាំងលើរាងកាយ និងទាំងពាក្យសម្ដី វាជារឿងញាប់ញ័រតក់ស្លុតបំផុត វានឹងអាចរាងចាល ។ ប៉ុន្តែ ការប្រព្រឹត្តរបស់កូន ពុំសមតាមបំណងប្រាថ្នាដ៏តក់ក្រហល់ភ្លាមៗទាំងស្រុងរបស់អ្នកនោះឡើយ ។ ចាំបាច់ណាស់ អ្នកជាមាតាបិតា ដែលស្ថិតក្នុងស្ថានភាពបែបនេះ គ្មានជម្រើសក្រៅពីអនុវត្តវិធី

ព្រៃផ្សៃបែបនេះទៀតឡើយ ។ ដូច្នេះ ជាលើកទី ២ ឬក៏បន្តបន្ទាប់ វាជាបញ្ហាធម្មតាដែលកូនលោកអ្នកបន្សាំបានទៅហើយ ឬពួកគេចាត់ទុកថា មាតាបិតារបស់ពួកគេតែប៉ុណ្ណឹង សាច់របស់ពួកគេជាសាច់រងកម្ម មិនបាច់ភ័យខ្វល់ខ្វាយ គេចរួចគឺរួច គេចមិនរួចតាមតែជាក់ស្ដែង ។ អាចថាលោកអ្នកជាកូនវិញម្ដង តើលោកអ្នកនឹងចេះគេចវេះ និងមានហិង្សាតបចំពោះអ្នកទាំងអស់ក្នុងគ្រួសារឬទេ ? តើគួរធ្វើដូចម្ដេច ដើម្បីរំដោះ ឬបញ្ចៀសឲ្យផុតពីបញ្ហាដ៏អាប់ឱននេះ ? គ្មាននរណាដោះស្រាយជំនួសបានឡើយ មានតែលោកអ្នកផ្ទាល់ប៉ុណ្ណោះ ថាតើទទួលស្គាល់អំពើរបៀបហិង្សាហ្នឹង ជាអំពើលាមកអធម ឬក៏ថាស្វែងយល់កែប្រែនូវអំពើខុសឆ្គងនេះ ? ឬក៏គួរប្រព្រឹត្តនូវអំពើណាដែលនាំមកនូវសេចក្ដីល្អប្រពៃ មិនពិបាករកទេ គឺលះបង់ការខ្មាសអៀនរបស់ខ្លួន សុំជំនួយគំនិតពីញាតិ ឬសិក្សារៀនសូត្រពីគ្រួសារដែលមានសុខសួស្ដី ។ ចៀសវាងអំពើយកកំហឹងទល់កំហាល់ ។ គួរចៀសនូវអំពើទាល់ច្រកនេះ (ដាំស្ពៅបានស្ពៅ ដាំស្រូវបានស្រូវ) ។

ដើម្បីជាកម្លាំងជំរុញ ឲ្យមានប្រសិទ្ធភាព ក្នុងការស្ដារនូវគ្រោះមហន្តរាយនេះ មានតែការជិតស្និទ្ធឲ្យកាន់តែខ្ទេឡើង និងមិនត្រូវលង់លក់ ឬងប់ងុលក្នុងភាពទំយើឡើយ ។ ត្រូវស្គាល់ច្បាស់អំពីការស្រឡាញ់និងការទំយើ ។ ស្រឡាញ់ គឺនាំមុខនិងគាំទ្រការប្រព្រឹត្តនូវគន្លងធម៌ ។ ឯការទំយើ គឺងប់ងុលគ្មានការទទួលស្គាល់កំហុស ទោះបីខុសក៏គាំទ្រ ដែលនាំមុខដោយអគតិ បានន័យថាមើលយល់ខ្លួននិងកូនខ្លួនសុទ្ធតែត្រូវល្អ ឆ្នើម អស្ចារ្យ និងហួតហួងជាងគេ ឯអ្នកដទៃគឺសុទ្ធតែមិនកើត អន់ ឬអាក្រក់ណាស់... ។ ម្យ៉ាងទៀតក្រោយពីដាក់ទណ្ឌកម្មលើរាងកាយរួចហើយ កូនកាន់តែប្រព្រឹត្តខុសគន្លងធម៌ រហូតប៉ះពាល់ទ្រព្យសម្បត្តិ ឬរាងកាយអ្នកដទៃ ឯលោកអ្នកជាមាតាបិតាមួយចំនួនខ្លះដែលមានកូនស្ថិតក្នុងស្ថានភាពអំពើពុំគប្បី បែរបរិហារថា អាកូននេះអាក្រក់ ឬអួតបង្ហាញប្រាប់គេថា ឪវាវាយស្ទើរសន្លប់ច្រើនដងហើយនៅតែមិនរាងចាល ។ នេះហើយការអួត ដើម្បីការពារភាពអាម៉ាស់ មិនតែប៉ុណ្ណោះអាចនឹងមានពាក្យបញ្ចោះជម្រុលផ្ដើនដាក់អ្នកដទៃក៏សឹងមាន ។

***ឧទាហរណ៍ :*** វាមិនល្អដូចកូនអ្នក បើវាជាកូនអ្នកវិញពុំដឹងថាស្រួលយ៉ាងម៉េចទេ? (ខ្លះថាហើយ ក៏សើចបញ្ឈឺទៀតផង) ឥរិយាបថនេះសបញ្ជាក់ថា ពុំត្រូវការគំនិតយោបល់ពីនរណាឡើយ ។

***ឧទាហរណ៍បែបបម្រាម :***

១. បើឃើញវា (កូន) ត្រូវការពារទ្រព្យ ការពារខ្លួន ខ្ញុំមិនទទួលខុសត្រូវនូវការខូចខាត ព្រោះអ្នកណាធ្វើអ្នកនោះទទួលខុសត្រូវ ។

២. អានេះគ្មានស្ដាប់ គ្មានខ្លាចនរណាទាំងអស់ !... ។ល។ និង ។ល។

គំនិតបែបនេះ គឺជាការយករួចខ្លួននឹងអាចជាជំហរគាំពារសកម្មភាពរបស់កូនទៀតផង ។

នេះជាឧទាហរណ៍សង្ខេបខ្លី ដែលតែងតែឃើញនិងឮជារឿយៗ ដើម្បីលើកយកមកវិភាគជាគំរូ និងនៅមានឥរិយាបថអវិជ្ជមានជាច្រើនយ៉ាងទៀត ។

(នៅមានត)

**លោក ផេង កែន**
ប្រធានការិយាល័យរដ្ឋបាលមន្ទីរ អ.យ.ក. ខេត្តកំពង់ឆ្នាំង




## របៀប វិធីផ្ទាល់ខ្លួន របស់គ្រូ ក្នុងការបង្រៀន (ត)

**ខ្ញុំសូមជូនឧទាហរណ៍មួយចំនួន ដូចខាងក្រោម ៖**

១. ដើម្បីឲ្យសិស្សចងចាំបានយូរ នូវឈ្មោះអ្នកអក្សរសាស្ត្រ និងកវីនិពន្ធជនជាតិបារាំងក្នុងសតវត្សទី ១៦ ទី ១៧ និងទី ១៨ លោកសាស្ត្រាចារ្យ ដែលបានបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ បានរើសយកឈ្មោះអ្នកនិពន្ធអក្សរសាស្ត្រ និងកវីទាំងនោះមួយចំនួនមកចងក្រងជាឃ្លា ដែលធ្វើឲ្យខ្ញុំនៅចាំឈ្មោះលោកទាំងនោះបានរហូតដល់សព្វថ្ងៃ ។

ខ្ញុំពុំអាចចាំបានថា លោកកវីនិពន្ធអក្សរសាស្ត្រឈ្មោះដូចខាងក្រោមនេះ រស់នៅក្នុងសតវត្សទីប៉ុន្មានច្បាស់លាស់ តែក្រោយពីការស្រាវជ្រាវ ខ្ញុំបានរកឃើញថា ៖

- Corneille (Pierre) poète français (1606-1684)
- Racine (Jean) poète écrivain (1639-1699)
- Rousseau (Jean Jacques) écrivain et philosophe (1712-1778)
- Boileau (Nicolas) écrivain (1636-1711)
- Fontaine (Charles) poète (1514-1570)
- Mme de Sévigné (Mari) Femme de lettres (1626-1696)

ខ្ញុំអាចស្រាវជ្រាវបានដោយងាយ ដោយសារខ្ញុំចាំឈ្មោះលោក អ្នកអក្សរសាស្ត្រនិងកវីនិពន្ធខាងលើនេះ តាមរយៈឃ្លាមួយដូចខាងក្រោម ៖

Corneille sur la Racine de Rousseau (rousseau) Boileau (Boit l´eau) de la Fontaine de Mme de Sévigné ។ តាមរយៈសូរស័ព្ទឈ្មោះអ្នកកវីនិពន្ធខាងលើនេះ ទោះបីពាក្យមិនត្រូវចំតាមអក្ខរាវិរុទ្ធទាំងស្រុងក៏ដោយអាចមានន័យជាភាសាខ្មែរដូចតទៅ ៖ (សត្វតាវ៉ៅនៅលើឫសទំពាំងបាយជូរក្រហមចុះផឹកទឹកអាងរបស់អ្នកស្រីដឹសេវីញេ)។

២. អតីតសាស្ត្រាចារ្យចិត្ត-គរុកោសល្យ និងសាស្ត្រាចារ្យភាសាខ្មែរមួយចំនួន ក្នុងការបង្រៀន បានរើសយកពាក្យដែលសរសេរ និង **ម** ដាក់ជើង **ដ** និង **ផ** ដាក់ជើង **ដ** មកសរសេរបង្ហាញដោយប្រុងប្រយ័ត្នខ្លាចភ័ន្តច្រឡំ រួចបង្កើតជាឃ្លា ដែលរណ្ដំពិរោះស្ដាប់ និងកំប្លែងមិនងាយភ្លេចដូចខាងក្រោម ៖

ក. ពាក្យសរសេរ និង **ម** ដាក់ជើង **ដ** → **ម្ដី ម្ដូរ ម្ដេចា ម្ដឹង** (ពេលនេះខ្ញុំប្ដេជ្ញា ប្ដឹង ប្ដូរ ប្ដី ហើយ)

ខ. ពាក្យសរសេរ និង **ផ** ដាក់ជើង **ដ** → **ផ្ដៀក ផ្ដាច់ផ្ដិល ផ្ដួល ផ្ដួចផ្ដើម ផ្ដេសផ្ដាស ផ្ដាំ ផ្ដន្ទា ផ្ដាសា** (ឯងកុំគិតផ្ដេសផ្ដាស អង្គុយលើគ្រែផ្ដៀក ដាក់ផ្ដាសាបើចង់ផ្ដន្ទាវាត្រូវតែផ្ដួចផ្ដើមផ្ដួលផ្ដាច់ផ្ដិល ឫសគល់ឲ្យវារាងចាល ផ្ដាំកូន ផ្ដាំចៅ) ។

៣. ពាក្យសរសេរនិង **ស-ន** ដាក់ជើង **ដ** និង **ស-ណ** ដាក់ជើង **ដ** ៖

ក. ពាក្យសរសេរ និង **ស-ន** ដាក់ជើង **ដ** ៖

**សន្ដាន សន្ដោស សន្ដាប ឬ (សណ្ដាប)** ។

ត្រូវបញ្ជាក់ប្រាប់សិស្សឲ្យចងចាំថាពាក្យដែលសរសេរ **ស-ន** ដាក់ជើង **ដ** នោះមានតែ ៣ពាក្យនេះទេ គឺ **សន្ដាន សន្ដោស** និង **សន្ដាប** → អាចសរសេរ (សណ្ដាប) ក៏បាន ។ សូមសន្ដោសវាផងព្រោះវាគ្មានញាតិសន្ដានទេ បើធ្វើបាប មុខជាវាឈឺក្ដៅសន្ដាបមិនខាន ។ ឯពាក្យក្រៅពីនេះត្រូវសរសេរដូចបញ្ជាក់ក្នុងចំណុច ខ ខាងក្រោម ៖

ខ. ពាក្យសរសេរនិង **ស-ណ** ដាក់ជើង **ដ** ៖

**សណ្ដ - សណ្ដក - សណ្ដង់ - សណ្ដាន់ - សណ្ដាយ - សណ្ដា - សណ្ដាប់ - សណ្ដូក - សណ្ដែក - សណ្ដាប (សន្ដាប) សណ្ដំ-សណ្ដោង-សណ្ដូន** ។ គួរតែងឃ្លាខ្លីៗ ៖

- ខ្នុរណាំងនេះដាំនៅដីសណ្ដ ពូជមិនសូវល្អឆាប់សណ្ដក សណ្ដង់ណាស់ ។
- ស្លម្ងរត្រីសណ្ដាយដាក់សណ្ដាន់ឆ្ងាញ់ជាងដាក់ស្លឹកសណ្ដា ។
- មនុស្សនេះឥតសណ្ដាប់ធ្នាប់ អង្គុយសណ្ដូកជើងស៊ីសណ្ដែកកួរ មិនយូរប៉ុន្មានក៏ក្ដៅសណ្ដាប ហើយដេកលក់ដូចគេសណ្ដំ ទោះបីគេសែងដាក់លើទូកសណ្ដោងយកទៅសណ្ដូនជុំថ្មពន្លិចទឹកក៏នៅតែមិនដឹងខ្លួនដែរ ។

៤. ពាក្យខ្លះសរសេរមាន «រ» ពាក្យខ្លះទៀតសរសេរគ្មាន «រ» ។ លោកសាស្ត្រាចារ្យបានរើសយកពាក្យស្មើនិងស្មើរមកសរសេរដាក់លើក្ដារខៀន រួចលោកបានពោលថា បើវាស្មើ ហើយចាំបាច់ទៅថែមអ្វីទៀត ។ ព្រោះតែវាស្មើរ ហើយទើបគេថែម «រ» ។

៥. ពាក្យ សុចរិត និង ទុច្ចរិត លោកបានពន្យល់ថា សុចរិត គឺល្អ ទៀងត្រង់ ពុំមានគំនិតអាក្រក់ដូចចោរទេ ដូចនេះសរសេរគ្មានជើង «ច» សរសេរ → សុចរិត ឯទុច្ចរិត គឺមិនល្អមានគំនិតជាចោរ ដូច្នេះ កុំភ្លេចជើង «ច» សរសេរ → ទុច្ចរិត ។

៦. ពាក្យបារាំងខ្លះៗដែលគួរចងចាំក្នុងការសរសេរ ដូចជាពាក្យ Tout le និង Tous les La canne និង la cane លោកសាស្ត្រាចារ្យបានប្រាប់ឲ្យចងចាំថា Tout le tout "t" Tous les tous "s" Exemple : Tout le monde Tous les éleves. La canne ដំបងសរសេរ n ពីរ La cane ទាញី សរសេរ n មួយ → ពីរជួននឹងញី ។

៧. ពាក្យខ្លះទៀតក្នុងភាសាបារាំង ដែលគួរចងចាំអំពីអត្ថន័យ ដូចជាពាក្យថា hypertension និង hypotension ។ ដើម្បីសិស្សងាយចងចាំអំពីអត្ថន័យ គេអាចបង្កើតជាពាក្យជូនគ្នាថា hyper en haut → hypo en bas ។

ដូច្នេះ hypertension = សម្ពាធឈាមឡើង

hypotension = សម្ពាធឈាមចុះ ។

មួយទៀត ដូចពាក្យ ក្អែកបួល និងកង្កែបយំ បារាំងប្រើកិរិយាសព្ទ coasser និង croasser ។
ដើម្បីកុំឲ្យច្រឡំ ត្រូវចំណាំ៖

coasser បន្ទាប់ពីអក្សរ c គឺ o = eau គឺទឹក នៅក្នុងទឹក គឺកង្កែប។

croasser បន្ទាប់ពីអក្សរ c គឺ r = air គឺ ខ្យល់ នៅក្នុងខ្យល់ គឺក្អែក។

ដូច្នេះ កង្កែបយំ = la grenouille coasse

ក្អែកបួល = le corbeau croasse

(នៅមានត)

**លោក គិម ប៊ុនសាន**

អតីត អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង អ.យ.ក.

## វិជ្ជាសម្បត្តិ

ហៃសាធុជនទាំងអស់គ្នា
មានគុណវិសេសធំទូលាយ
មិនលំបាកទុកស្រណុកលាក់
មិនខ្លាចចោរលួចឬចោរប្លន់
ឥតកណ្តៀរកោរកណ្តុរកាត់
ប្រើច្រើនកើតច្រើនចម្រើនទៀង
មានសុវិជ្ជាគង់មានទ្រព្យ
មានមិត្តហើយបុណ្យតែងរត់រក

ចំណោះវិជ្ជាទាំងសម្ងាយ[1]
គួរយើងវេចស្តាយកុំខ្លាចធ្ងន់ ។
ជាជាងមាសប្រាក់សព្វទ្រព្យធន
ទៅគ្រប់តំបន់គ្រាន់ជាស្បៀង ។
ចាយណាស់មិនបាត់មិនមានល្អៀង
ពីបច្ចុប្បន្នវៀងទៅបរលោក ។
អ្នកផងមិនស្អប់មិត្តមូលមក
ស្លាប់ទៅបរលោកយោគស្ថានសួគ៌ ។

ពូរ អ៊ុម

(វេយ្យាករណ៍ ១៩៥៣)

1=ធម្មតាៗ សាមញ្ញ ភាយរង បន្ទាប់បន្សំ

# អភិវឌ្ឍន៍របៀបធ្វើការជាក្រុម (តចប់)

ដើម្បីធានានូវការងារជាក្រុមឲ្យជាប់មិនដាច់នោះ នាយកសាលាគប្បីបានដឹងនូវគ្រប់សកម្មភាពរបស់គ្រូបង្រៀន ដើម្បីអាចផ្ដល់ជូនគេវិញនូវព័ត៌មានត្រឡប់ជាបន្តបន្ទាប់ជូនពួកគេ និងជួយពួកគេឲ្យធ្វើការកែលម្អបានសមស្រប ។ វិធីដ៏ល្អមួយ គឺការនិយាយដោយផ្ទាល់ តត្ដ ជាមួយគ្រូម្នាក់ៗ ។ ដោយហេតុនេះ នាយកអាចប្រមូលបាននូវគំនិតថ្មីៗថែមទៀត ហើយក៏អាចផ្ដល់ព័ត៌មានត្រឡប់ប្រកបដោយប្រសិទ្ធភាពជូនគ្រូបង្រៀន ។

នៅពេលដែលរបៀបធ្វើការជាក្រុមដំណើរការទៅបានល្អនោះ វានឹងលេចចេញមកជាច្រើននូវគំនិតថ្មីៗប្រកបដោយភាពច្នៃប្រឌិត ។ នាយកសាលាគប្បីមានទេពកោសល្យក្នុងការសម្របសម្រួលឲ្យគំនិតថ្មីៗទាំងនោះបានជ្រួតជ្រាបទៅគ្រប់ទិសទីក្នុងសាលារៀន និងប្រសិនបើអាចធ្វើបាន ប្រមូលគំនិតថ្មីៗពីខាងក្រៅមកឲ្យពួកគេថែមទៀត ។

នៅក្នុងសាលារៀនដែលឯតទគ្គកម្មក្រុម (Team Performance) មិនមានការប្រែប្រួលនោះ សមាជិកក្រុមនឹងមានអារម្មណ៍ព្រងើយ និងមិនមានការជំរុញទឹកចិត្ត ។ នាយកសាលាគប្បីយល់នូវស្ថានភាពនេះ ហើយជានិច្ចកាលធ្វើការទទូចឲ្យគ្រូបង្រៀននិងបុគ្គលិកសម្លឹងទៅរកស្ដង់ដារខ្ពស់សម្រាប់ពួកគេ ។ ប្រសិនបើអាចធ្វើបាន គួរពិភាក្សាគ្នាបង្កើតឲ្យបាននូវឧត្ដមគតិក្រុម (Team Spirit) ហើយនៅរាល់ពេលដែលមានការនិយាយជាមួយពួកគេ ត្រូវរំឭកជានិច្ចនូវសារៈសំខាន់នៃការធ្វើការជាក្រុមនេះ ។ នេះជាមធ្យោបាយមួយដើម្បីរក្សាពួកគេឲ្យធ្វើចលនាទៅរកអនាគតជានិច្ច ។

របៀបធ្វើការជាក្រុមទាមទារឲ្យគ្រូបង្រៀននិងបុគ្គលិកទាំងអស់ជួបជុំជាមួយគ្នា និយាយគ្នា ធ្វើការសន្ទនាជាមួយគ្នា ធ្វើការរួមគ្នា ។ ដូចនេះ នាយកសាលាគួរតែផ្ដល់ជូនពួកគេនូវសម្ភារៈនិងថវិកាសម្រាប់អនុវត្តនូវសកម្មភាពទាំងនេះ ព្រមទាំងផ្ដល់នូវពេលវេលាសម្រាប់ពួកគេធ្វើការជាមួយគ្នាផង ។ ក្នុងករណីនេះ សាលាគួរតែមានបន្ទប់មួយដែលមានសម្ភារៈនិងធនធានគ្រប់គ្រាន់សម្រាប់ពួកគេ ។

ក្រុមដែលល្អត្រូវមាននូវបទបញ្ញាមួយដែលចងភ្ជាប់សមាជិកក្រុមឲ្យបានជិតស្និទ្ធជាមួយគ្នា ។ បទបញ្ញា គឺជាការរំពឹងទុកអំពីឥរិយាបថរបស់សមាជិកម្នាក់ៗ ។ បទបញ្ញារបស់ក្រុមគួរជាគំនិតរបស់សមាជិកក្រុមម្នាក់ៗ ដើម្បីឲ្យក្រុមធ្វើការបានល្អ នាយកសាលាគួរតែសម្របសម្រួលឲ្យបុគ្គលិកនិងគ្រូបង្រៀនម្នាក់ៗធ្វើការជាមួយគ្នា បង្កើតនូវបទបញ្ញាមួយដែលពួកគេមានការឯកភាពគ្នា ។

នៅគ្រប់កម្មវិធី ឬសកម្មភាព រមែងលេចចេញនូវបុគ្គលដែលលេចធ្លោ ជាអ្នកឈានមុខក្នុងការច្នៃប្រឌិត ឬបង្កើតនូវគំនិតថ្មី ។ នាយកសាលាត្រូវទទួលស្គាល់និងលើកទឹកចិត្តអ្នកទាំងនេះ ព្រមទាំងផ្ដល់រង្វាន់ដល់គេផង ។

នៅប្រទេសកម្ពុជា យើងមិនមានទម្លាប់របៀបធ្វើការជាក្រុមទេ ដូចនេះយើងទទួលស្គាល់ថា ការកសាងក្រុមការងារល្អក្នុងសាលារៀនពិតជាមានការលំបាក ទាមទារនូវការខំប្រឹងប្រែងមួយ។ទោះជាយ៉ាងណាក៏ដោយ នាយកសាលាត្រូវតែជឿជាក់ថា ការអភិវឌ្ឍវិធីធ្វើការជាក្រុម ជាលក្ខខណ្ឌជាសារវន្តសម្រាប់ការកសាងសាលារៀនល្អមួយ ហើយឥរិយាបថគំរូរបស់ខ្លួនក្នុងការងារនេះគឺជាការចាំបាច់ ។

**លោក អ៊ឹម សារីក**

# សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា (ត)

## ២. បណ្ណាល័យ

ស្ថិតនៅជាន់ទី ១ បណ្ណាល័យផ្ដល់ជូនសៀវភៅសិក្សាសម្រាប់អាន និងសម្រាប់ឲ្យសិស្សនិងគ្រូខ្ចី ។ តុអានក៏បានផ្ដល់ជូនផងដែរនៅក្នុងបរិស្ថានស្ងប់ស្ងាត់មួយ។បណ្ណាល័យបើកទ្វារតាមម៉ោងសិក្សារបស់សិស្ស ។ បណ្ណារក្សមួយរូប ជួយសម្រួលការអានរបស់សិស្ស ។

## ៣. បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ

បន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំងពីរដែលស្ថិតនៅជាន់ផ្ទាល់ដីមានបរិក្ខារ និងសម្ភារៈទំនើបសម្រាប់ឲ្យគ្រូនិងសិស្សធ្វើពិសោធន៍ងាយៗបន្ថែមលើការសិក្សាទ្រឹស្ដី សិស្សត្រូវការពិសោធន៍ជាក់ស្ដែង ដើម្បីលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្ររបស់គេ ។ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រនីមួយៗ មានអ្នកថែរក្សាម្នាក់ ។ សិស្សអាចសិក្សាដោយការធ្វើតាមវិធីអនុវត្តជាក់ស្ដែងមួយ ដើម្បីពង្រឹងអ្វីដែលពួកគេសិក្សាតាមរយៈមេរៀននិងការអាន ។

## ៤. បន្ទប់ប្រជុំ

សាលប្រជុំដែលស្ថិតនៅជាន់ទី ១ មានម៉ាស៊ីនត្រជាក់ ប្រដាប់បញ្ចាំង LCD មួយសម្រាប់ការធ្វើបទបង្ហាញ ។ សាលប្រជុំនេះ គឺធំល្មមសម្រាប់ទទួលអ្នកចូលរួមប្រជុំបានដល់ ១០០នាក់។ បន្ទប់មួយទៀតនៅទល់មុខបន្ទប់ប្រជុំ គឺសម្រាប់រៀបចំភេសជ្ជៈនិងពិភាក្សាគ្នាពេលឈប់សម្រាក។ បន្ទប់ប្រជុំនេះក៏អាចជួលឲ្យអតិថិជនមកពីក្រៅបានដែរ សម្រាប់កិច្ចការប្រជុំ សិក្ខាសាលា និងសកម្មភាពបណ្ដុះបណ្ដាលផ្សេងៗ ។

## ៥. បន្ទប់គ្រូ

បន្ទប់គ្រូដែលស្ថិតនៅជាន់ផ្ទាល់ដី មានសង្ហារឹមសមរម្យ ។ បន្ទប់នេះគឺជាកន្លែងសម្រាប់ឲ្យលោកគ្រូអ្នកគ្រូជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍និងប្ដូរចំណេះដឹងថ្មីៗ ។

## ៦. បរិក្ខារផ្សេងៗ

បន្ថែមលើបរិក្ខារខាងលើ មានការិយាល័យមួយចំនួនសម្រាប់នាយក នាយករង គ្រូវិទ្យាសាស្ត្រ និងគ្រូកុំព្យូទ័រ ។ បន្ទប់អនាម័យចំនួន ២ មួយសម្រាប់បុរស និងមួយទៀតសម្រាប់ស្ត្រី ។ ក្រៅពីនេះ ក៏ត្រូវការនូវប្រព័ន្ធបណ្ដាញទឹក បណ្ដាញភ្លើងជាប្រចាំ ដើម្បីឲ្យអគារធនធានមានដំណើរការបានយ៉ាងល្អ ព្រោះថា អគារធនធានដែលពោរពេញទៅដោយសម្ភារបច្ចេកវិទ្យាទំនើបសម្រាប់បង្កើនសមត្ថភាពសិស្សឲ្យកាន់តែល្អ រវាងទ្រឹស្ដីនិងការអនុវត្ត ដោយផ្សារភ្ជាប់ទ្រឹស្ដីក្នុងមេរៀន និងការពិសោធវិទ្យាសាស្ត្រ ។ មជ្ឈមណ្ឌលនៃបច្ចេកវិទ្យាទាំងអស់នេះ គឺមិនបម្រើត្រឹមតែវិទ្យាល័យរបស់ខ្លួនទេ ថែមទាំងជួយដល់បណ្ដាញសាលាឯទៀតដែលត្រូវការមកសិក្សានៅទីនេះ ។

## ៧. លទ្ធផល

ជាការលើកស្ទួយគុណភាពនិងសមធម៌នៃការអប់រំនៅកម្ពុជា ជាមួយការអប់រំនៅមធ្យមសិក្សាកាន់តែមានប្រសិទ្ធភាព សកម្មភាពគ្រូបង្រៀនក៏កាន់តែល្អ និងប្រព័ន្ធគ្រប់គ្រងក៏កាន់តែរឹងមាំ បើតាមលក្ខណៈសម្បត្តិនៃសម្ភារបច្ចេកវិទ្យានិងការណែនាំរបស់ក្រសួងអប់រំ នោះសិស្សម្នាក់ៗដែលសិក្សានៅសាលាធនធាន ក៏ដូចជាសាលាបណ្ដាញ ពិតជាទទួលបានចំណេះដឹង ជំនាញ ភាសាអង់គ្លេស កុំព្យូទ័រ និងចំណេះដឹងបែបវិទ្យាសាស្ត្រជាច្រើនទៀត ប៉ុន្តែជាទូទៅពុំទាន់បានទទួលលទ្ធផលល្អប្រសើរនៅឡើយទេ ដោយសារកត្តាសន្យានុម័ត និងអត្តនោម័តមួយចំនួនដូចជា ៖

- រវាងចំណេះដឹងនៃការប្រើប្រាស់អគារធនធាន ក៏ដូចជាការប្រើប្រាស់សម្ភារៈនានាផងដែរ ក្នុងអគារធនធាន និងគ្រូភាគច្រើនពុំបានទទួលការបណ្ដុះបណ្ដាល តម្រូវឲ្យមានការបណ្ដុះបណ្ដាលពីរបៀបប្រើប្រាស់និងការគ្រប់គ្រង ព្រមទាំងអត្ថប្រយោជន៍នៃសម្ភារៈទាំងអស់នោះ តាមរយៈក្រុមពិសោធន៍ដែលធ្លាប់មានស្នាដៃឆ្នើម ក្នុងការប្រើប្រាស់សម្ភារៈទំនើបដើម្បីជួយដល់លោកគ្រូ អ្នកគ្រូឲ្យបានយល់កាន់តែច្បាស់លាស់ ។ជាមួយគ្នានេះ គួរតែបើកសិក្ខាសាលាបណ្ដុះបណ្ដាលដល់គ្រូបង្គោលសម្រាប់ប្រចាំវិទ្យាល័យ ក្នុងទិសដៅជាទីប្រឹក្សាដ៏ល្អសម្រាប់លោកគ្រូ អ្នកគ្រូវិទ្យាសាស្ត្រ ។ ការបណ្ដុះបណ្ដាលនេះត្រូវធ្វើឲ្យបានច្រើនដង ហើយក៏សំណូមពរឲ្យមន្ទីរអប់រំក៏ដូចក្រសួងអប់រំ បញ្ជូនក្រុមអធិការកិច្ច ឬក៏អ្នកចុះវាយតម្លៃពីលទ្ធផលនៃការពិសោធ ការធានាពីដំណើរការនៃអគារធនធានឲ្យបានត្រឹមត្រូវ គួរជៀសវាងការវាយតម្លៃខុសជំនាញ ។

- គម្លាតគ្នារវាងសមត្ថភាពគ្រូវិទ្យាសាស្ត្រ ព្រោះគ្រូវិទ្យាសាស្ត្រខ្លះក្នុងសាលាធនធាន និងសាលាបណ្ដាញមានសមត្ថភាពជាគ្រូកម្រិតមូលដ្ឋាន ទទួលបានការបណ្ដុះបណ្ដាលតិចតួចណាស់ (ខ្លះជាគ្រូបឋមហើយមានសញ្ញាបត្រទុតិយភូមិ និងទទួលបានការបណ្ដុះបណ្ដាលក្នុងរយៈពេលតែ ២ វិស្សមកាល ក៏បានក្លាយជាគ្រូកម្រិតមូលដ្ឋាន) ដែលជាហេតុនាំឲ្យចំណេះដឹងផ្នែកវិទ្យាសាស្ត្រពួកគេនៅមានកម្រិត (គ្រូមានសមត្ថភាពទាបជាងសម្ភារៈ) ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវការប្រជុំក្រុមបច្ចេកទេសឲ្យបានញឹកញាប់ ព្រោះថាវាបានផ្លាស់ប្ដូរនូវចំណេះដឹង បទពិសោធន៍ វិធីសាស្ត្របង្រៀន ក្នុងនោះក៏បានប្ដូរគ្នាពីសមត្ថភាពគ្រូនិងសិស្សលើការពិសោធផងដែរ ។ លោកគ្រូ អ្នកគ្រូវិទ្យាសាស្ត្រ ទាមទារនូវសម្ភារៈជា Video ដើម្បីឲ្យគ្រូនិងសិស្សបានមើលនូវការពិសោធដែលទទួលបានជោគជ័យនៅកន្លែងផ្សេងៗ ។

- ជាមួយគ្នានេះបណ្ដាញ ទឹក ភ្លើង វត្ថុធាតុដើមសម្រាប់ពិសោធន៍ គ្រឿងបន្លាស់កុំព្យូទ័រ គឺជាកត្តាសំខាន់ដែលតម្រូវឲ្យមានជាប្រចាំ ប៉ុន្តែជាក់ស្ដែងលោកគ្រូ អ្នកគ្រូតែងតែត្អូញត្អែរពីការផ្គត់ផ្គង់មិនទាន់ពេលវេលា ដែលជាប្រការមួយធ្វើឲ្យការសិក្សារបស់សិស្សមិនបានល្អ ។ ការអញ្ជើញលោកគ្រូ អ្នកគ្រូតាមសាលាបណ្ដាញមកចូលរួមប្រជុំបច្ចេកទេសក៏ជាការពិបាកមួយដែរ ព្រោះថាផ្លូវឆ្ងាយ ការឧបត្ថម្ភនៅមានកម្រិតទាបនាំឲ្យការចូលរួមនៅមានកម្រិត ។

( នៅមានត )

**លោក គួយ សុគាន**

ចំណោទ

# ផ្គុំប្រធានចំណោទសារឡើងវិញ

**វត្ថុបំណង**

- អានព័ត៌មានផ្សេងៗ
- ពន្យល់ព័ត៌មានផ្សេងៗ
- ចោទជាសំណួរ
- ធ្វើឲ្យមានទំនាក់ទំនងគ្នានូវព័ត៌មានដែលបានមកពីប្រភពផ្សេងៗ ។

## ១. គោលបំណងរបស់សលាកប័ត្រ

- ដឹកនាំសិស្សឲ្យវិភាគព័ត៌មានចំណោទ កាលណាគំនិតសំខាន់ៗនៃចំណោទនីមួយៗ ស្ថិតនៅលាយឡំគ្នា គ្មានសណ្ដាប់ធ្នាប់ ។
- ជំរុញសិស្សឲ្យចេះអានគំនិតសំខាន់ៗ នៃចំណោទដោយប្រុងប្រយ័ត្នបំផុត ។

***ចំណោទ***

- នេះជាចំណោទចំនួន ៣ដែលបិតនៅលាយឡំគ្នា ។
- ចូរផ្គុំបំណែកអត្ថបទទាំងនេះ ដើម្បីបង្កើតជាចំណោទចំនួន ៣ឡើងវិញ ។

| | | |
|---|---|---|
| **ក**. ឯថ្ងៃបន្ទាប់គាត់បានលក់ ៥,៥០ម ច្រើនជាងថ្ងៃទីមួយ ។ | **ខ**. ម្ដាយខ្ញុំលក់ផ្លែឈើទទួលបានប្រាក់ ៨៦៧ ០០០៛ ។ | **គ**. បន្ទាប់មកគាត់ក៏បានបន្តដំណើរពីស្គន់ទៅដល់កំពង់ចាមនៅវេលាម៉ោង ៩ : ៥៥ ។ |
| **ឃ**. នៅម៉ោង ៨ : ៥៥ គាត់បានមកដល់ស្គន់ ហើយឈប់សម្រាកនៅទីនោះ ១០នាទី ។ | **ង**. និងអាគុយមួយដែលមានតម្លៃថោកជាងទូរទស្សន៍ ១៦៥ ៣០០៛ ។ | **ច**. អ្នកលក់កំណាត់សំពត់ម្នាក់មានកំណាត់មួយគឺដែលមានប្រវែង ៦៥ម ។ |
| **ឆ**. គាត់បានទិញទូរទស្សន៍មួយគ្រឿងតម្លៃ ២៩៨ ០០០៛ ។ | **ជ**. ថ្ងៃទីមួយគាត់លក់អស់ ២៥ម ។ | **ឈ**.មីងវិមលបានចេញដំណើរពីភ្នំពេញនៅម៉ោង ៦ : ៤៥ ។ |

- ចំពោះចំណោទនីមួយៗ ចូរបង្កើតសំណួរឲ្យបានមួយ ។

ចូរគណនានិងសរសេររបៀបឆ្លើយ ។

## ២. ការរៀបចំរបស់គ្រូ

- គ្រូត្រូវចម្លងចំណោទដាក់ក្ដារខៀនមុនម៉ោងបង្រៀន ឬរៀបចំដាក់ផ្ទាំងក្រដាសធំ(បើមានលទ្ធភាព)។
- គ្រូត្រូវត្រៀមរៀបចំបំណែកនីមួយៗរបស់អត្ថបទខាងលើនេះលើផ្ទាំងក្រដាស ដើម្បីងាយស្រួលក្នុងការបូកសរុប ។

## ៣. លំនាំនៃការបង្រៀន

**ដំណាក់កាលទី ១ : អំណាននិងការយល់អត្ថន័យនៃអត្ថបទ**

- ឲ្យសិស្សអានចំណោទទាំង ៣ ដោយស្ងៀមស្ងាត់ ។
- ទុកពេលគ្រប់គ្រាន់ឲ្យសិស្សអាន ។
- គ្រូសួរ (ម្ដងមួយសំណួរៗ) ៖
  ១. តើនៅលើក្ដារខៀនមានចំណោទប៉ុន្មាន ?
  ២. តើចំណោទទាំងនោះរៀបរយហើយឬនៅ ?
  ៣. តើចំណោទនេះគេឲ្យយើងធ្វើអ្វីខ្លះ ?
- ឲ្យសិស្សឆ្លើយឲ្យបានច្រើននាក់ចំពោះសំណួរនីមួយៗ ។
- ឲ្យសិស្សផ្ទៀងផ្ទាត់ ផ្ទួរផ្ទងចម្លើយ និងជួយកែលម្អ ។
- គ្រូពន្យល់បន្ថែមនិងជួយបំពេញចំណុចខ្វះខាត ។
- ឲ្យសិស្សដទៃទៀតតាមដាន ផ្ទៀងផ្ទាត់ និងកែលម្អ ។

**ដំណាក់កាលទី ២ : ដោះស្រាយចំណោទ**

➢ ការស្រាវជ្រាវលើកទី ១ : *ជ្រើសរើសនិងផ្គុំព័ត៌មានផ្សេងៗឲ្យបានជាចំណោទ* ៖

**សំណូមពរ :** ចំពោះការស្រាវជ្រាវនេះ កូនៗទាំងអស់គ្នាត្រូវធ្វើនៅលើក្ដារឆ្នួន ដោយកត់ត្រាតែព្យញ្ជនៈរបស់បំណែកនីមួយៗនៃអត្ថបទ ដើម្បីផ្គុំវាឲ្យបានជាចំណោទត្រឹមត្រូវ ប៉ុន្តែមិនចាំបាច់តាក់តែងសំណួរទេ ។

- គ្រូត្រូវបញ្ជាក់នូវសំណូមពរនេះដោយយឺតៗ ឲ្យបានពីរ ឬបីដង ។
- ឲ្យសិស្សស្រាវជ្រាវ និងផ្គុំបំណែកនៃចំណោទទាំងនោះឲ្យបានចំណោទ ៣ (ការងារជាបុគ្គល) ។
- ទុកពេលគ្រប់គ្រាន់ឲ្យសិស្សស្រាវជ្រាវ ។

គ្រូដើរពិនិត្យមើលការងាររបស់សិស្សដើម្បីជួយជំរុញពួកគេឲ្យរកឃើញចំណោទទាំង៣នោះ ។

សំណួមពរ :

- ឲ្យសិស្សលើកក្ដារឆ្នួន ។
- គ្រូផ្ទៀងផ្ទាត់ចម្លើយរបស់សិស្ស ។
- ប្រសិនបើមានចម្លើយផ្សេងៗគ្នា គ្រូត្រូវឲ្យសិស្សទាំងនោះឡើងមកបង្ហាញចម្លើយរបស់គេដោយឲ្យអានអត្ថបទចំណោទដែលគេបានរកឃើញនោះ និងឲ្យធ្វើអំណះអំណាងបញ្ជាក់ ដោយគ្រូចោទជាសំណួរ « ចូរកូនពន្យល់ថា តើកូនធ្វើដូចម្ដេចទើបអាចផ្គុំព័ត៌មានទាំងនោះឲ្យក្លាយជាចំណោទមួយបាន ? តើមានចំណុចណាខ្លះដែលបង្ហាញដល់កូនឲ្យរកឃើញ ? » ។
- គ្រូកត់ត្រាចម្លើយរបស់សិស្ស (ឧទាហរណ៍ : ច ជ ក ... ) ឬយកបំណែកអត្ថបទមកបិទតគ្នាទៅតាមចម្លើយរបស់សិស្ស ។
- ឲ្យសិស្សអានអត្ថបទចំណោទនោះ (អំណាន៣) ។
- ឲ្យសិស្សឯទៀតផ្ទៀងផ្ទាត់និងជួយកែលម្អដោយមានការអះអាងបញ្ជាក់ ។
- គ្រូត្រូវឲ្យសិស្សបញ្ចេញយោបល់ឲ្យបានច្រើននាក់ ។
- គ្រូពន្យល់បន្ថែមនិងជួយបំពេញចំណុចខ្វះខាត ។
- គ្រូត្រូវអនុវត្តដូចលំនាំខាងលើនេះ ចំពោះចំណោទ ២ទៀត ។

(នៅមានត) ដកស្រង់ដោយ **លោកស្រី ម៉ុន សារ៉ន**

## ត្រូវគោរពប្រណិប័តន៍ឪពុកម្ដាយយើង

ចូរអស់កុមារទាំងឡាយអើយ អ្នកកើយត្រូវកោតខ្លាចមេបា
ព្រោះលោកមានគុណធ្ងន់អស្ចារ្យ ប្រាថ្នាចង់ឲ្យតែកូនល្អ ។
ក្នុងលោកនេះរកអ្នកឯណា អាសូរករុណាដោយស្មោះសរ
ដូចឪពុកម្ដាយយើងនេះក្រៃ អ្នកក្រៅកម្រយ៉ាងនេះឡើយ ។
ត្រូវយើងកោតខ្លាចឲ្យប្រាកដ បើគាត់ទូន្មានកុំឆ្លងឆ្លើយ
ត្រូវប្រណិប័តន៍តាមកុំកន្តើយ អ្នកកើយលោកប្រាប់ខុសត្រូវណាស់ ។
ក្មេងណាមិនកោតខ្លាចមេបា ធំឡើងកាលណាខូចស្រឡះ
មិនបានចេះដឹងអ្វីជ្រៅជ្រះ ដូច្នេះច្រើនណាស់មិនដែលល្អ ។
ជួនទៅជាខូចជាលួចប្លន់ គេទាន់ចាប់បានដាក់ខ្នោះក
គេវាយបណ្ដើរយំឡូឡា ដូច្នេះមិនល្អកុំធ្វើតាម ។

(ស្រង់ពីកិច្ចសិក្សាឆ្នាំ ១៩៣២)







## ១. ការណែនាំអំពីគេហទំព័រគ្រូ

គេហទំព័រគ្រូ ត្រូវបានអភិវឌ្ឍឡើងដោយក្រសួងអប់រំយុវជន និងកីឡា និងធ្លាប់បានសហការជាមួយអង្គការ វីវីអូប៊ី ក្នុងគោលបំណងផ្តល់ជូននូវធនធានឌីជីថលដ៏សម្បូរបែបតាមបណ្តាញអ៊ីនធឺណិត ដល់គ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវ សិស្សានុសិស្ស និងសាធារណជនទូទៅ ។ ទន្ទឹមនឹងនេះ គេហទំព័រគ្រូក៏បានអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចបញ្ចូលរាល់ស្នាដៃរបស់ខ្លួនដែលបានស្រាវជ្រាវ ដើម្បីចែករំលែកដល់អ្នកផ្សេងទៀតតាមរយៈទំព័របណ្តាញនេះផងដែរ ។ គេហទំព័រគ្រូ មានអ្នកប្រើសកម្មចំនួន ៨៨៩នាក់ បានចុះឈ្មោះចូលរួមចំណែកដាក់បញ្ចូលឯកសារនិងមានឯកសារអប់រំ ប្រមាណ ៩៦២ឯកសារ រួមមាន ឯកសារពហុមេឌៀ អន្តរកម្ម ផ្ទាំងរូបភាព កិច្ចតែងការ វីដេអូពិសោធន៍វិទ្យាសាស្ត្រ អប់រំគរុកោសល្យ និងឯកសារយោងដទៃផ្សេងទៀត ។ ចំនួនអ្នកប្រើប្រាស់និងអត្ថបទនឹងបន្តកើនឡើងជាលំដាប់ ដោយការដាក់បញ្ចូលដោយក្រុមការងារក្រសួងនិងអ្នកប្រើប្រាស់ ។

ដើម្បីធានាបានគុណភាព និងខ្លឹមសារឯកសារដែលដាក់បញ្ចូលដោយអ្នកប្រើ ត្រូវបានត្រួតពិនិត្យដោយក្រុមការងារ គេហទំព័រគ្រូមុននឹងសម្រេចធ្វើការបែងចែកផ្សាយដល់អ្នកប្រើប្រាស់ ។

## ២. ការចូលដំណើរការគេហទំព័រគ្រូ

លោកអ្នកអាចចូលទៅកាន់គេហទំព័រគ្រូតាមរយៈអាសយដ្ឋាន <u>www.krou.moeys.gov.kh</u> ដែលនឹងនាំលោកអ្នកមកដល់ទំព័រដើម ដូចរូបខាងក្រោម ៖




*រូបភាពទី ១ : ទំព័រដើមរបស់គេហទំព័រគ្រូ krou.moeys.gov.kh*

## ៣. ទំព័រហ្វេសប៊ុកផ្លូវការរបស់គេហទំព័រគ្រូ

បន្ថែមលើគេហទំព័រគ្រូ លោកអ្នកក៏ធ្វើការតាមដានអត្ថបទថ្មីៗពីគេហទំព័រគ្រូ តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់គេហទំព័រគ្រូបានផងដែរ ដោយគ្រាន់តែចុច " Like " តាមរយៈអាសយដ្ឋាន facebook.com/krou.moeys.gov.kh ឬស្វែងរកឈ្មោះទំព័រ Krou Cambodia លើប្រអប់ស្វែងរកលើគណនីហ្វេសប៊ុករបស់អ្នក ។




*រូបភាពទី២ : ទំព័រហ្វេសប៊ុកផ្លូវការរបស់គេហទំព័រគ្រូ fb.com/krou.moeys.gov.kh*

## ៤. កម្មសិទ្ធិបញ្ញានិងជំនួយបច្ចេកទេស

រាល់ខ្លឹមសារ (រួមទាំងខ្លឹមសាររបស់អ្នកប្រើប្រាស់) ដែលបានបង្ហោះលើគេហទំព័រនេះ ស្ថិតក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-NonCommercial-ShareAlike 3.0 License (CC BY 3.0) ដែលលោកអ្នកអាចប្រើប្រាស់ ចែករំលែក ឬកែលម្អបន្ថែមដោយគ្រាន់តែបញ្ជាក់ប្រភពអ្នកផលិត ។ សូមចូលទៅកាន់អាសយដ្ឋាន **krou.moeys.gov.kh/license** ដើម្បីសិក្សាបន្ថែមពីអាជ្ញាប័ណ្ណលើគេហទំព័រគ្រូ ។




*រូបភាពទី ៣ : អាជ្ញាប័ណ្ណរបស់គេហទំព័រគ្រូ*

ប្រសិនបើអ្នកមានបញ្ហាចំពោះការប្រើប្រាស់ ឬដាក់បញ្ចូលអត្ថបទលើគេហទំព័រ សូមទំនាក់ទំនងមកកាន់ក្រុមការងារបច្ចេកទេសតាមរយៈទូរស័ព្ទ ៖ ០២៣ ២១០ ១៣៨ ឬអាសយដ្ឋានអ៊ីមែល ៖ **krou@moeys.gov.kh** ។

*សូមអញ្ជើញលោកគ្រូ-អ្នកគ្រូ អ្នកសិក្សាស្រាវជ្រាវ សិស្សានុសិស្ស និងសាធារណជនទូទៅចូលរួមប្រើប្រាស់និងផ្ដល់មាតិកាអត្ថបទដល់គេហទំព័រគ្រូតាមរយៈតំណ ៖* **www.krou.moeys.gov.kh** *តាមការគួរ ។*

រៀបរៀងដោយលោក **តែល តារុណា**

កែសម្រួលលោក **សុក ថា**

នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន




កំណាព្យៈ

## ម៉ែ........
(បទកាកគតិ)

- ម៉ែគឺជាព្រះ មាននៅក្នុងផ្ទះ នៅក្នុងលោកា
  គ្មាននរណាម្នាក់ គ្មានសោះឡើយណា ម៉ែផ្ដល់សង្ខារ
  គឺជាព្រះដើម ។

- ម៉ែជាគ្រូច្បង បង្រៀនសាសង ពីរោះដំឆ្មើម
  ប្រើពាក្យសំដី គ្រប់តែដង្ហើម ហេតុតែគ្រូដើម
  ចង់ឲ្យកូនចេះ ។

- ម៉ែជាអ្នកច្រៀង បីបមផ្អួងផ្អៀង គ្មានទាល់តម្រិះ
  បំពេរកូនតូច ដោយប្រើចំណេះ កូនគេងលក់ចេះ
  ពីរោះបំពេរ ។

- ម៉ែជាបេឡា ផ្ដល់ថវិកា មិនដែលថាទេ
  ឲ្យតែកូនត្រូវ ម៉ែខំរិះរេ ទោះអត់ខ្ចីគេ
  ឲ្យតែកូនបាន ។

- ម៉ែជាចុងភៅ ដាំស្លទុកនៅ ចានឆ្នាំងចង្ក្រាន
  រៀបចំទុកដាក់ ពេលកូនវិលថ្កាន ពីសាលាបាន
  កូនបរិភោគ ។

- ម៉ែជាអ្នកថៃ ពេលកូនត្អូញត្អែរ ឈឺចុករាករោគ
  ទ្រាំអត់ងងុយ អង្គុយងក់ងោក ខ្លួនទទឹកជោក
  ទឹកមូត្រលាមក ។

- ម៉ែនៅមានច្រើន យើងគួរក្រវើន[1] មិនគួរលង់លក់
  ភ្លេចគុណបំណាច់ ខោអាវបោកគក់ កន្ទបលាមក
  គេងលក់អង្រឹង ។

- ម៉ែជាអ្វីៗ ស្រេចកូនប្រុសស្រី រំពៃរំពឹង
  គុណលោកប៉ុនណា ស្រេចកែវព្រលឹង កុំរឹងទទឹង
  បំភ្លេចគុណម្ដាយ ៕

**លោក ធីវ សុផល**
នាយកសាលាបឋមដំរីយកទឹក ស្រុកសំរោង ខេត្តតាកែវ

1-ក្រវើនៈឧស្សាហ៍ខ្នះខ្នែងប្រឹងប្រែង

# ការងារកសិកររដូវវស្សា

## (បទពាក្យប្រាំពីរ) (តចប់)

- រង់ចាំសំណាបគ្រប់កំណត់ ប្រជានឿយហត់អំណត់ក្រៃ
  ភ្ជួរដាស់បន្តរៀងរាល់ថ្ងៃ តាមចំនួនដីកម្មសិទ្ធិផ្ទាល់ ។
- ស្រែវាលស្រែបឹងប្រឹងរិះគិត លុះដោយគំនិតគិតឲ្យដល់
  លើកភ្លឺបានខ្ពស់ជួយតម្កល់ ទឹកច្រើនមិនខ្វល់ស្រួលប្រែដី ។
- ការងារដកស្ទូងមានបែបបទ ដល់ពេលប្រាកដត្រូវលកលៃ
  រសៀលដកបានប្រមាណដី ភ្ជួរប្រែរាស់ថ្មីស្ទូងបន្ត ។
- អ្នកគ្មានឧបករណ៍គោក្របី ធ្វើប្រវាស់ដៃច្រើនកុះករ
  ខ្លះប្រើគោយន្តជាឧបករណ៍ ភ្ជួររាស់ឈ្នួលរល្អពេកក្រូវ ។
- ខ្លះជួយដកស្ទូងប្រើគំនិត អស់ប្រាក់មែនពិតតែបានស្រូវ
  ហូបចុកគ្រប់គ្រាន់មានសល់នៅ ដោះដូរគ្រប់ផ្លូវត្រូវទាំងអស់ ។
- វស្សានរដូវស្រូវពេញស្រែ លូតលាស់ហូរហែប្រែសម្រស់
  ទេសភាពលម្អល្អឥតខ្ចោះ វាលស្រូវព្រំប្រោះស្រស់សន្ធឹក ។
- រសៀលត្រជាក់ធ្លាក់ជំនោរ ភ្លឺដាច់ទឹកហូរស្ទួររអឹក
  ប្រជៀវឆ្លៀលឆ្វាត់ស្វែងរកចឹក ចំណីរដឹកច្រើនដេរដាស ។
- ចចាតបក្សីល្បីហិចហើរ មៀងមើលបណ្ដើរបានឃើញច្បាស់
  ចំណីក្នុងទឹកប្រឹងរូតរះ បោះពួយរហ័សប៉ះទឹកខ្វាយ ។
- សត្វក្ដុំពួនយំសែនស្រណោះ រណ្ដំពិរោះសំឡេងសាយ
  មនុស្សប្រុសស្រីផងទាំងឡាយ រំភើបរីករាយជាអនេក ។
- វស្សាភ្លៀងច្រើនកើនការងារ ច្រើនឥតគណនាពុំរារែក

| | | |
|---|---|---|
| បោចស្មៅត្រៀមដីគ្មានអល់អែក | ពិនិត្យបំបែកពួកសត្វក្រា | ។ |
| - កណ្ដុរដង្កូវមមាចត្នោត | វិធានពិសោធន៍ជាតម្រា | |
| ប្រជាត្រូវមានធម៌មេត្តា | ចូលរួមចលនាជួយការពារ | ។ |
| - សត្វមានប្រយោជន៍ជីវិតរស់ | រួចចាកផុតគ្រោះរស់គ្រប់គ្រា | |
| ជាសណ្ដានសត្វពូជអ្នកជា | បំផ្លាញពាធាសត្វល្អិតបាន | ។ |
| - គប្បីស្វែងយល់ស៊ីជម្រៅ | ប្រើថ្នាំត្រឹមត្រូវតាមលម្អាន | |
| ច្បាប់អភិរក្សបរិស្ថាន | ផ្ដល់សុខក្សេមក្សាន្តតរៀងទៅ | ។ |

**លោក ប្រាក់ សាចាត់**
អតីតប្រធានការិយាល័យ អប់រំ យុវជន និងកីឡា
ស្រុកបន្ទាយមាស ខេត្តកំពត

**ចីរកាលនៃវត្តឧណ្ណាលោម**

វត្តឧណ្ណាលោម បើនិយាយពីប្រវត្តិនៃមហាចេតិយកណ្ដាលខាងលិចវិហារសព្វថ្ងៃនេះ និងព្រះពុទ្ធរូបថ្មអង្គធំក្នុងរូងនៃមហាចេតិយនោះ ពុំដឹងជាកើតមានពីក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយ៍អង្គណា ពីក្នុងពុទ្ធសតវត្សរ៍ទីប៉ុន្មានទេ ប៉ុន្តែ បើនិយាយពីត្រឹមរជ្ជកាលនៃព្រះបាទសម្ដេចព្រះបរមរាជា (ពញាយ៉ាត) ដែលព្រះអង្គមានព្រះរាជបញ្ជាឲ្យកសាងវត្តនេះឡើងវិញទៀត ហើយទ្រង់ធ្វើបុណ្យបញ្ចុះសីមានៅថ្ងៃ ១១កើត ខែពិសាខ ឆ្នាំច ចត្វាស័ក ព.ស ១៩៨៦ គិតពីឆ្នាំនោះមកដល់ឆ្នាំខាលចត្វាស័ក ព.ស ២៥០៥ នេះ ឃើញថាមានចីរកាល ៥១៩ឆ្នាំ ឬ៥២០ ឆ្នាំហើយ ។

ដកស្រង់ពីប្រវត្តិនៃវត្តឧណ្ណាលោម
សម្ដេចព្រះមហាសុមេធាធិបតី ជួនណាត
ជោតញ្ញាណោ (១៩៦៣)




## ពុទ្ធសាសនានៅប្រទេសកម្ពុជា (ត)

វប្បធម៌ឥណ្ឌាខាងពុទ្ធសាសនា ដែលមាននៅលើភូមិភាគអាស៊ីអាគ្នេយ៍អាចចែកជាមជ្ឈមណ្ឌលពុទ្ធសាសនា ៦មណ្ឌល គឺ : (3)

១. **បុព្វទិសាភាគ** : ប្រទេសចម្ប៉ាជាដែនដីជនជាតិចាមពីអតីតកាល ប្រទេសនេះធ្លាប់កាន់ពុទ្ធសាសនា មាននិកាយ ២ គឺ អរិយសម្មតិនិកាយ ១ សវាស្តិវាទនិកាយ ១ ។ មានព្រះពុទ្ធរូបសំរឹទ្ធិមួយអង្គល្អវិសេស ការរចនាបែបអមរាវតី នៅស្រុកដុងដឿង (Dong dung) ខេត្តខ្វាងណាម (Quang nam) ពីពុទ្ធសតវត្សរ៍ទី ៣ ឬទី ៤ ។

២. **បុព្វទិសមជ្ឈិមភាគ** : ប្រទេសនគរភ្នំ (Funan) គឺប្រទេសកម្ពុជាបច្ចុប្បន្ន ។ ប្រភពចិនចែងថា ព្រះបាទហ៊ុនទៀន ព្រះនាងលីវយី = កៅណ្ឌិន្យ នាគីសោមា = ព្រះថោងនាងនាគី ជាបឋមក្សត្រិយ៍ស្ថាបនាប្រទេសនេះឡើងកាលពីគ្រិស្តសតវត្សរ៍ទី ១ ។ មានសិលាចារឹកពុទ្ធសាសនាបរមបុរាណជាងគេបង្អស់នៅឥណ្ឌូចិន ជាព្រះរាជប្រកាសរបស់ព្រះបាទ ហ្វាន់ចេម៉ុន គឺស្រីមារៈ ពីក្នុងគ្រិស្តសតវត្សរ៍ទី ២ ឬទី ៣ មានសិលាចារឹកបុរាណ ៤ និងពុទ្ធរូបជាច្រើនជាសក្ខីភាព ។

៣. **បស្ចិម ទិសមជ្ឈិមភាគ**:ដែនដីមន (រាមញ្ញប្រទេស) និងខ្មែរ គឺប្រទេសសៀមសព្វថ្ងៃ ។ មានចក្រចារថា យេ ធម្មា ... នៅបុរាណដ្ឋាននគរបឋម ។ ការរចនាចក្រនេះ មិនមែនមានមុនគ្រិស្តសតវត្សរ៍ទី ៦ ទេ ។ មានព្រះពុទ្ធរូបសំរឹទ្ធិមួយអង្គនៅបុរាណដ្ឋានពងទឹក (Pong Tug) ការរចនាបែបអមរាវតី គ្រិស្តសតវត្សរ៍ទី ៣ ឬទី ៤ ។ មានព្រះពុទ្ធរូបសំរឹទ្ធិមួយអង្គទៀត ការរចនាបែបអមរាវតីដែរ គេរកឃើញនៅនគររាជសីមា ។ ព្រះពុទ្ធរូបទាំងនេះចេញមកពីសាលាភ្នំជាអង្គរបុរី ខេត្តតាកែវ ។

3 *សៀវភៅពុទ្ធសាសនា ២៥០០ ដោយព្រះមហាវីរិយបណ្ឌិត ប៉ាង ខាត់*

៤. **បស្ចិមទិសាភាគ** : ប្រទេសមន (រាមញ្ញប្រទេស) គឺប្រទេសភូមាសព្វថ្ងៃនេះ មានសន្លឹកមាស ច្រើនសន្លឹកចារថា យេ ធម្មា ... នៅម៉ាហ្សា (Maza) និងម៉ោងគាន (Moung gan) ជិតក្រុងប្រោម (Prome) ពីគ.ស.ទី ៥ ។ ទីក្រុង ថាទុង (Thaton) ជាក្រុងចាស់ឈ្មោះ សុធម្មវតី ឬសុធម្មបុរៈ ដែលចិនហៅថា ស្រីក្សេត្រៈ ក្នុងគ.ស.ទី ៧ ។

៥. **ជ្រោយម៉ាឡាយូ** : ប្រភពចិនចែងថា នៅទីនោះមានរដ្ឋតូចៗកាន់តាមវប្បធម៌ឥណ្ឌាតាំងពីគ្រិស្ដសតវត្សរ៍ទី ២ តែសិលាចារឹកក្នុងទីនេះមិនមានមុនគ្រិស្ដសតវត្សរ៍ទី ៤ឡើយ ។

៦. **ប្រជុំកោះទាំងឡាយ** : មានសិលាចារឹកច្រើនកន្លែង ។ សិលាចារឹកព្រះបាទ មូលវរ្ម័នក្នុងស្រុក កុតី (Kutei) នៅកោះ បរណេអូ ពីខាងដើមគ.ស.ទី ៥។សិលាចារឹកព្រះបាទបូណ៌វរ្ម័ននៅបស្ចិមភាគកោះជ្វាកាលពីរវាងគ.ស.ទី ៥ដែរ ។ មានព្រះពុទ្ធរូប " ទីបង្ករៈ ព្រះពុទ្ធជាទីពឹង " ច្រើនអង្គ ការរចនាបែបអមរាវតី មួយអង្គរកឃើញនៅស្រុក សេមប៉ាគា (Sempaga) ក្នុងកោះសេឡេប (Celebes) មួយអង្គទៀតរកឃើញនៅខេត្ត ជេមប៊ែរ (Jamber) ប្រទេសជ្វាខាងបុព្វទិស និងមួយអង្គទៀតរកឃើញលើទួលសេគុនតាំង (Seguntang) នៅកោះបាឡេមបាំង (សុមាត្រា) ចិនហៅកោះជ្វានេះថា យេ៉ចាវ (Ye tiao = Java dipa) ពីគ.ស. ១៣២ ។


ព្រះភក្ត្រព្រះពុទ្ធនៅវត្តរលក អង្គបុរី ខេត្តតាកែវ
នៅសម័យគ.ស.ទី ៦ - ទី ៧ សព្វថ្ងៃនៅសារមន្ទីរភ្នំពេញ

ព្រះមហាវីរិយបណ្ឌិត ប៉ាង ខាត់ សរសេរទុកថា « យើងបានប្រមូលឯកសារខាងលើនេះមកត្រិះរិះមើលឃើញថា ទីឋានទាំងនេះមានពុទ្ធសាសនាផ្សាយមកដល់ ហើយបើយកសករាជមកផ្ទៀបគ្នាមើលទៀត ឃើញថា មិនមុនមិនក្រោយជាងគ្នាប៉ុន្មានទេ តែបើសិនជាយកសិលាចារឹកពុទ្ធសាសនាសំស្ក្រឹតនៅស្រុកវ៉ូកាញ់ ដែលបរមបុរាណជាងគេមកជាមូលដ្ឋានវិញនោះ យើងនឹងអាចពោលបានថា ពុទ្ធសាសនាមកដល់ប្រទេសនគរភ្នំ (ហ្វូណន) អតីតកម្ពុជា មុនជាងទីឋានសុវណ្ណភូមិឯទៀតទាំងអស់» ។

**(នៅមានត)**

**លោក ជ័យ សយ្យនា**

ដកស្រង់ចេញពីសៀវភៅពន្លឺពុទ្ធសាសនា

រៀបរៀងដោយ **សោម ខន**

# សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ (ត)

លោកសាស្ត្រាចារ្យ **John Dewey** បានបញ្ជាក់ទៀតថា លើពិភពលោកយើងនេះការទាក់ទងគ្នារវាងជីវិតក្នុងសាលារៀន និងជីវិតក្នុងសហគមន៍មានសារៈប្រយោជន៍ដ៏សំខាន់។ វត្ថុដ៏សំខាន់ជាងគេបំផុតនៅក្នុងខ្លួនមនុស្សដែលយើងបានពិចារណានិងទទួលបានពីការអប់រំនៅក្នុងសាលារៀន គឺបានមកពីទម្រង់សកម្មភាពផ្សេងៗគ្នា តាមរយៈមុខវិជ្ជាជាច្រើនដែលបានសិក្សានៅក្នុងសាលារៀន និងបានស្ថិតនៅក្នុងស្មារតីរបស់មនុស្ស ។ វាបានផ្លាស់ប្តូរដោយរួមបញ្ចូលគ្នាជាមួយជីវិតជាក់ស្តែង ហើយបានប្រែក្លាយទៅជាទម្លាប់របស់កុមារ ដែលគេបានរៀនតាមរយៈការរស់នៅប្រចាំថ្ងៃ និងជំនួសនូវអ្វីដែលគេបានរៀនបែបអរូបី ទៅជាលក្ខណៈបែបរូបី ព្រមទាំងជាបទពិសោធន៍សម្រាប់អនាគតទៀតផង ។ វាបានផ្លាស់ប្តូរទៅជាផ្នាំងទស្សនីយភាពរបស់សហគមន៍និងរឿងរាវផ្សេងៗរបស់សង្គម ។ ទាំងអស់នេះ ជាមូលដ្ឋានពិតមួយដែលបានលេចឡើងជាបន្តបន្ទាប់នៃក្តីស្រមៃក្នុងការបង្រៀន ។

លោក **K.G.Saiyidian** យល់ថាភាពកំសោយនាពេលបច្ចុប្បន្ន នៃតួនាទីប្រព័ន្ធសាលារៀននៅក្នុងប្រទេសឥណ្ឌា គឺមនុស្សមិនទាន់ទទួលស្គាល់ការពិត និងមិនអាចស្វែងរកការពិតបាននោះទេ ។ សាលារៀនជាគ្រឹះស្ថានសិក្សាមួយដែលមានតួនាទីពន្យល់ និងសាកល្បងពិចារណាលើការពិត ។ គោលបំណងនៃការសិក្សាអនុវត្តទាំងអស់ គឺមានទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាលដូចជា ច្បាប់តុលាការ ឬពន្ធនាគារជាដើម ។

លោក **Ryburn** បានពិពណ៌នាថា ទំនាក់ទំនងគ្នារវាងសាលារៀននិងសហគមន៍ត្រូវតែមានការទ្រទ្រង់ផ្នែកទំនាក់ទំនង រវាងជីវិតសិស្សនៅក្នុងសាលារៀន និងជីវិតនៅក្នុងសហគមន៍ ដែលពួកគេបានបញ្ចប់ការសិក្សា ហើយអាចរកការងារធ្វើបាន។ គេក៏ត្រូវតែមានការទ្រទ្រង់ផ្នែកទំនាក់ទំនងរវាងសាលារៀននិងជីវិតសិស្ស ជីវិតគ្រូបង្រៀននៅក្នុងសហគមន៍ដែរ ។ បើពុំធ្វើដូចនេះទេ សាលារៀនពិតជាពុំបានទទួលជោគជ័យនៅក្នុងគោលដៅរបស់ខ្លួន ហើយសិស្ស នឹងប្រឈមមុខជាមួយបញ្ហាសង្គម សិស្សនឹងមិនអាចបំពេញតម្រូវការរបស់សង្គមបានទេ ។

### ហេតុអ្វីបានជាគេរៀបចំសាលារៀនទៅជាមជ្ឈមណ្ឌលនៃសហគមន៍ ?

(Why should we make the school as a community centre ?)

១. ទស្សនៈទ្រឹស្តីសង្គមវិជ្ជាអប់រំបែបទំនើបបានលើកឡើងថា សាលារៀនគួរតែប្រកាន់ភ្ជាប់នូវជីវិតនិងសកម្មភាពសង្គមតាមរយៈមុខវិជ្ជាផ្សេងៗ និងតាមរយៈវិធីសាស្ត្រការងារ ។ គេត្រូវតែមានមនសិការ និងការចូលរួមបន្ត ដែលផ្តល់ដោយសេរីតាមរយៈសកម្មភាពក្នុងសាលារៀននិងក្រៅសាលា ។ សាលារៀនគួរតែផ្តល់ឱកាសឲ្យសិស្សចូលរួមនៅក្នុងសេវាសង្គម ការឃោសនា

យុទ្ធនាការសុខភាព និងសកម្មភាពសាធារណៈផ្សេងៗទៀត ។ ការចែកដាច់គ្នារវាងសាលារៀន និងជីវិតពិតក្នុងសង្គមប្រៀបបានជាការបង្រៀនហត្ថកម្មដែលខ្វះនូវគុណភាព ។

២. សាលារៀនមិនមែនជាកន្លែងសហគមន៍ដែលកុមារត្រូវទទួលចំណេះដឹងទាំងស្រុងនោះទេ :

- រួមជាមួយនឹងការវិនិយោគថវិកានៅក្នុងសំណង់អគារសាលារៀន និងសម្ភារៈបរិក្ខារ ។ វាជាស្ថានភាពសេដ្ឋកិច្ចដ៏ក្រីក្រព្រមទាំងទស្សនវិជ្ជាអប់រំដ៏អាក្រក់មួយចំពោះលក្ខខ័ណ្ឌ ដែលគេត្រូវប្រើ ២ឬ ៣ម៉ោងក្នុងមួយថ្ងៃ ឬរយៈពេល ២ទៅ ៣ខែក្នុងមួយឆ្នាំ ។
- អគារសាលារៀននិងគ្រឿងបរិក្ខារ ត្រូវបានគេបើកជាសាធារណៈក្រោយពេលបទបញ្ញត្តិផ្ទៃក្នុងត្រូវបានគេអនុម័តហើយ ។

៣. គ្រូនឹងមានឱកាសក្លាយទៅជាអ្នកដឹកនាំក្នុងសង្គម និងលើកកម្ពស់នូវតួនាទីនិងមុខងាររបស់គេ ។

**តើគេគួរធ្វើដូចម្ដេចដើម្បីឲ្យមជ្ឈមណ្ឌលសាលារៀនក្លាយទៅជាសេវាកម្មសហគមន៍ ?**

(How to make the school a center of community service ?)

១. កម្មវិធីសិក្សាត្រូវតែទាក់ទងជាមួយជីវិតពិតក្នុងសង្គម :

- ការសិក្សានៅក្នុងសាលារៀនត្រូវតែទាក់ទងជាមួយជីវិតនៅខាងក្រៅ ។ កម្មវិធីសិក្សាដែលមានមុខវិជ្ជាប្លែកៗគ្នា គេគួរតែធ្វើផែនការដោយប្រុងប្រយ័ត្ន ដោយដាក់រួមជាមួយបញ្ហាជាច្រើននៅក្នុងសង្គម ។ កម្មវិធីសិក្សាគួរឆ្លុះបញ្ចាំងទៅលើអ្វី ដែលជាគុណប្រយោជន៍និងជាចរិតលក្ខណៈនៃជីវិតនៅក្នុងសហគមន៍ ។
- ចំពោះតំបន់ជនបទ លោក **Saiyidian** បាននិយាយថា សាលារៀនគួរតែជួយកុមារឲ្យទទួលយកបញ្ហាសមភាព តថភាពនៃជីវិតនៅក្នុងជនបទ និងបណ្ដុះបណ្ដាលពួកគេឲ្យទទួលយកជីវិតពិតនៅក្នុងសង្គម ហើយគេអាចស្វែងរកការងារបានបន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សា ។ ស្រដៀងគ្នានេះ មុខវិជ្ជាខាងឧស្សាហកម្មដែលសិក្សានៅក្នុងសាលារៀន ។ ក្រោយពេលពួកគេបានបញ្ចប់វគ្គ កុមារអាចប្រើប្រាស់និងដំណើរការនៃគ្រឿងបរិក្ខារផ្នែកឧស្សាហកម្មនោះនៅក្នុងរោងចក្រ ទាំងបច្ចេកទេសនិងការប្រើប្រាស់ ។

**គួយ សុគាន**
សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

(នៅមានត)

# ប្រព័ន្ធលេខក្នុងភាសាខ្មែរ

នៅក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ៤៦ ខ្ញុំបានជម្រាបជូនរួចមកហើយ អំពី "ប្រព័ន្ធបកតិសំខ្យាខ្មែរ "ស្រាវជ្រាវឃើញក្នុងវចនានុក្រមសម្ដេច **ជួន ណាត** ក្នុងអភិធានប្បទីបិតាបាថ និងក្នុងឯកសារហ្លួងពិភក្តិធានីសម្របសម្រួលបញ្ចូលគ្នានោះ យើងបានឃើញថាប្រព័ន្ធលេខខ្មែររាប់ឡើងមានឈ្មោះហូរហែរហូតដល់១អសង្ខេយ្យដែលមានសូន្យដល់ទៅ១៤០។ ប៉ុន្តែក្នុងការប្រើប្រាស់ជាក់ស្ដែងកន្លងមក រហូតដល់បច្ចុប្បន្ននេះត្រូវទាល់ត្រឹមពាន់លាន ឬ លានលាន (១ ០០០ ០០០ ០០០ ០០០ឬ ១០$^{១២}$) សូម្បីតែពាក្យកោដិក៏ប្រើខុស ច្រឡំថាស្មើនឹង ១ពាន់លានដែលតាមពិត ១កោដិ គឺ ១០លានតែប៉ុណ្ណោះ។ រីឯចំនួនធំៗទៅលើទៀតចាប់ពី១បកោដិ ដែលស្មើនឹងមួយរយសែនកោដិពុំដែលឃើញមាននរណាគេប្រើសោះឡើយ។

បច្ចុប្បន្ននេះ ដោយប្រទេសជាតិមានការរីកចម្រើនជាបន្តបន្ទាប់ ការប្រើប្រាស់លេខក៏មានតម្រូវការកាន់តែធំទៅៗនោះ រាជរដ្ឋាភិបាល ក៏បានសម្រេចកំណត់ឲ្យប្រើប្រាស់ប្រព័ន្ធលេខក្នុងភាសាខ្មែរ សម្របតាមប្រព័ន្ធលេខខ្ទីពីអង់គ្លេស US ចាប់ពីប៊ីលាន (billion $10^9$) ឡើងទៅដោយសម្រួលការអានព្យាង្គចុងជាលានបែបខ្មែរ ដើម្បីឲ្យមានការឯកភាពគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធលេខក្នុងភាសាខ្មែរ និងដើម្បីឲ្យប្រព័ន្ធលេខខ្មែរ មានសនិទានភាពជាងប្រព័ន្ធលេខខ្មែរបុរាណ។

យោងតាមសំណើ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ចុះថ្ងៃ ២៥ មិថុនា ២០១៥ និងចំណារឯកភាពរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រីបានចេញ សជណ លេខ១០២៦ នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥ កំណត់ឲ្យប្រើប្រាស់ប្រព័ន្ធលេខក្នុងភាសាខ្មែរ ដូចខាងក្រោម៖

ដប់,១រយ,១ពាន់,១០ពាន់(១ម៉ឺន),១០០ពាន់(១សែន),១លាន,១០លាន,១០០លាន នៅដដែលដូចដើម ។ តែចាប់ពី ១០០០លានឡើងទៅត្រូវយកឈ្មោះថ្មីគឺ៖

១ប៊ីលាន = ១០០០ ០០០ ០០០ (១០$^{៩}$)<br>
១ទ្រីលាន = ១០០០ ០០០ ០០០ ០០០ (១០$^{១២}$)<br>
១ក្វាទ្រីលាន = ១០០០ ០០០ ០០០ ០០០ ០០០ (១០$^{១៥}$)<br>
១គ្វីនទីលាន = ១០០០ ០០០ ០០០ ០០០ ០០០ ០០០ (១០$^{១៨}$)<br>
១សិចទីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{២១}$)<br>
១សិបទីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{២៤}$)<br>
១អុកទីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{២៧}$)<br>
១ណូនីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{៣០}$)<br>
១ដេស៊ីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{៣៣}$)<br>
១អាន់ដេស៊ីលាន = ១០០០ ០០០ ០០០ ០០០ ------- ------ (១០$^{៣៦}$)<br>
១០អាន់ដេស៊ីលាន= ១០០០ ០០០ ០០០ ០០០ ------------- (១០$^{៣៧}$)<br>
ចប់ត្រឹម ១០០ អានដេស៊ីលាន= ១០០០ ០០០ ០០០ ០០០--- (១០$^{៣៨}$)។

# សរសេររៀបឈ្មោះជាតារាង ដើម្បីងាយយល់ ងាយចាំ ងាយប្រើ

| ឈ្មោះ | ស្វ័យគុណ |
|---|---|
| អាន់ដេស៊ីលាន | ($១០^{៣៦}$) |
| ដេស៊ីលាន | ($១០^{៣៣}$) |
| ណូនីលាន | ($១០^{៣០}$) |
| អុកទីលាន | ($១០^{២៧}$) |
| សិបទីលាន | ($១០^{២៤}$) |
| សិចទីលាន | ($១០^{២១}$) |
| ក្វីនទីលាន | ($១០^{១៨}$) |
| ក្វាទ្រីលាន | ($១០^{១៥}$) |
| ទ្រីលាន | ($១០^{១២}$) |
| ប៊ីលាន | ($១០^{៩}$) |
| លាន | ($១០^{៦}$) |
| ពាន់ | ($១០^{៣}$) |

១ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ០០០

ការកំណត់ខាងលើនេះ សង្កត់តែលើឈ្មោះប្រព័ន្ធលេខជាភាសាខ្មែរ តែពុំបានកំណត់ផងទេ ពីរបៀបសរសេរថាត្រូវសរសេរបីខ្ទង់ដកឃ្លាបន្តិចឬទេ? ត្រូវប្រើចំណុចឬប្រើក្បៀស?នៅខ្ទង់ណា? តើត្រូវអានដូចម្តេច?

ឧ- ៥,២៥ ប៊ីលាន,អានថា ៥ក្បៀស ២៥ប៊ីលាន ឬ ជា ៥ ប៊ីលាន ២៥? ។ល។

តែទោះជាយ៉ាងណា ការកំណត់ឲ្យប្រើប្រពន្ធ័លេខក្នុងភាសាខ្មែរ ពិតជាជំហានមួយធំក្នុងការអភិវឌ្ឍប្រពន្ធ័លេខក្នុងភាសាខ្មែរ ដែលយើងត្រូវជួយគាំទ្រផ្សព្វផ្សាយដើម្បីអនុវត្តប្រើប្រាស់ឲ្យបានឯកភាពគ្នាតទៅ។

**លោក យស់ អ៊ាង**

## អ្នករៀន កុំរៀនៗទៅ ត្រូវតាំងចិត្តផងថា ៖

រៀនថ្ងៃហ្នឹង ចាំថ្ងៃហ្នឹង យល់ថ្ងៃហ្នឹង
ចាំដោយប្រឹង ខំទន្ទេញ ខំហាត់ថា
យល់ដោយប្រឹង គិតសង្កេត ពិចារណា
ចាំនិងយល់ លោកហៅថា ការរៀនចេះ ។
ច្នេះត្រូវផ្ទង់ ខំតម្រង់ សោតវិញ្ញាណ
ព្រមទាំងមាន ស្មារតីចាំ ត្រង់ចំណេះ
គ្រូប្រាប់អ្វី គប្បីចាំ រួចត្រិះរិះ
រៀនឲ្យចេះ ឲ្យចេះឆាប់ ឲ្យចិតថេរ ។
យើងកុំខ្ជិល យើងខ្មើមខ្ជិល យើងខ្មាសខ្ជិល
ខ្ជិលមន្ទិល នាំឲ្យភ្លេច នាំថោកកេរ្តិ៍
យើងឧស្សាហ៍ ក្នុងការរៀន កុំទំនេរ
ទើបបំបែរ កែអង្គខ្លួន ជាប្រាជ្ញបាន ។

យូរ អុន (កម្ពុជសុរិយា ១៩៥១)

## ចំណាប់អារម្មណ៍របស់លោក សេក ណាន គ្រូបង្រៀនភាសាខ្មែរដែលមានស្នាដៃបង្រៀនសិស្សបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០១៤-២០១៥ និទ្ទេស A ពិន្ទុភាសាខ្មែរបាន ១២១/១២៥

ជាបឋម ខ្ញុំបាទសូមគោរពឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សូមគោរពឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូ និងភ្ញៀវកិត្តិយសដែលមានវត្តមានក្នុងកម្មវិធីនេះទាំងអស់ជាទីគោរពដ៏ខ្ពង់ខ្ពស់។

ខ្ញុំបាទឈ្មោះ សេក ណាន ជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យ ហ៊ុន សែន ក្រវ៉ា ស្ថិតក្នុងខេត្តកំពង់ធំ។ ថ្ងៃនេះរូបខ្ញុំបាទមានកិត្តិយសនិងសេចក្ដីរំភើប សប្បាយរីករាយ ជាពន់ពេក ដែលត្រូវក្រសួងអប់រំ យុវជន និងកីឡាអនុញ្ញាតឲ្យថ្លែងអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន។

ឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូ និងភ្ញៀវកិត្តិយសជាទីគោរព ចំពោះខ្ញុំបាទយល់ឃើញថាភាពជោគជ័យរបស់គ្រូបង្រៀន គឺស្ដែងឡើងតាមរយៈលទ្ធផលល្អ របស់សិស្សានុសិស្ស។ តាមបទពិសោធន៍នៃការបង្រៀនរបស់ខ្ញុំកន្លងមក ខ្ញុំយល់ឃើញថាដើម្បីឲ្យសិស្សទទួលបានលទ្ធផលល្អគ្រូត្រូវ៖

-ប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងវិជ្ជាជីវៈជាគ្រូបង្រៀន។

-ចេះបង្ហាញនិងបំផុសអំពីតម្លៃនិងសារប្រយោជន៍នៃមុខវិជ្ជារបស់ខ្លួន ឲ្យសិស្សបានដឹងព្រោះកាលណាសិស្សស្គាល់អំពីតម្លៃនិងសារប្រយោជន៍ពិតប្រាកដនៃមុខវិជ្ជាណាមួយហើយនោះ ពួកគេនឹងខិតខំប្រឹងប្រែងរៀនសូត្រជាមិនខានឡើយ។

-បណ្ដុះទឹកចិត្តសិស្សឲ្យស្រឡាញ់ចូលចិត្តមុខវិជ្ជារបស់ខ្លួន តាមរយៈវិធីសាស្ត្រ និងសមត្ថភាពនៃការបង្រៀនប្រកបដោយភាពច្បាស់លាស់និងសប្បាយរីករាយ។

-ពង្រីកនិងពង្រឹងចំណេះដឹងរបស់ខ្លួនជាប្រចាំតាមរយៈការស្វ័យសិក្សានិងស្វ័យស្រាវជ្រាវដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្ទេរចំណេះដឹងថ្មីៗដល់សិស្ស។

-ឲ្យសិស្សហ្វឹកហាត់ការប្រឡងសាកល្បងដែលមានលក្ខណៈស្តង់ដាលើខ្លឹមសារនិង រយៈពេលដើម្បីវាស់ស្ទង់សមត្ថភាពរបស់សិស្សមុនការប្រឡងពិតប្រាកដ។

-ចេះតាមដានលទ្ធផលនៃការប្រឡងរបស់សិស្សលើមុខវិជ្ជារបស់ខ្លួនធៀបនឹងមុខវិជ្ជាផ្សេងឬធៀបនឹងលទ្ធផលរបស់សិស្សក្នុងសាលាផ្សេង រកឲ្យឃើញនូវចំណុចខ្សោយនិងចំណុចខ្លាំងនៃការបង្រៀនរបស់ខ្លួន។

ជាចុងបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូ និងភ្ញៀវកិត្តិយសទាំងអស់សូមឲ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលំ កុំបីឃ្លៀងឃ្លាតឡើយ។សូមអរគុណ!

## ចំណាប់អារម្មណ៍របស់លោក លី ឡៃហេង គ្រូបង្រៀនគណិតវិទ្យាដែលមានស្នាដៃបង្រៀនសិស្សបានប្រឡងជាប់សញ្ញាប័ត្រ មធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា ២០១៤-២០១៥ និទ្ទេស A ព្រមទាំងបានពិន្ទុគណិតវិទ្យា ១២៥/១២៥

ជាបឋមខ្ញុំបាទសូមគោរពឯកឧត្តម លោក លោកស្រីដែលជាភ្ញៀវចូលរួមទាំងអស់ជាទីគោរព និងជាទីរាប់អាន។

ខ្ញុំបាទឈ្មោះ លី ឡៃហេង ជាគ្រូកំរិតឧត្តមឯកទេសគណិតវិទ្យានៃ វិទ្យាល័យ ១០ មករា ១៩៧៩ ខេត្តសៀមរាប។ ខ្ញុំបានរៀនចប់ជាគ្រូបង្រៀនកំរិតឧត្តមតាំងពីឆ្នាំ១៩៩៦ ដោយសារកង្វះខាតគ្រូបង្រៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញនាយកសកលវិទ្យាល័យក៏បានដកខ្ញុំទុកបង្រៀននៅទីនេះ ក្រោយមកដោយបញ្ហាជីវភាព គ្មានកន្លែងស្នាក់នៅនិងមានតែឪពុកហើយគាត់កាន់តែចាស់ផង ខ្ញុំក៏បានសម្រេចចិត្តសុំផ្ទេរពីភ្នំពេញមកខេត្តកំណើត ហើយក៏បង្រៀននៅ វិទ្យាល័យ ១០ មករា ១៩៧៩ ដែលជាអតីតវិទ្យាល័យខ្ញុំបានរៀនពីមុន។ ដោយសារតែការស្រលាញ់មុខវិជ្ជាគណិតតាំងពីនៅរៀនផង និងចូលចិត្តបង្រៀនឲ្យគេយល់ពីគណិតវិទ្យាផងនោះ ខ្ញុំខិតខំរកវិធីសាស្ត្រស្រាវជ្រាវបង្រៀនសិស្ស ធ្វើយ៉ាងណាឲ្យសិស្សឆាប់យល់និងឆាប់ចេះ មិនយូរមិនឆាប់សិស្សរបស់ខ្ញុំជាច្រើនជំនាន់ និងជាច្រើននាក់បានទទួលនិទ្ទេស A និងបានអាហាររូបករណ៍ចេញទៅរៀននៅក្រៅប្រទេសជាក់ស្តែងកូនស្រីរបស់ខ្ញុំឈ្មោះលី ហេងរីណា ក៏បានទទួលនិទ្ទេស A នៅឆ្នាំនោះដែរ ហើយនាងបានទទួលអាហាររូបករណ៍ទៅរៀននៅប្រទេស ស្វីស មុនពេលប្រលងសញ្ញាប័ត្រនេះ។ លទ្ធផលទាំងនេះបានមកពីការខិតខំប្រឹងប្រែងដោយមិនគិតពីការនឿយហត់។

មុនពេលចាប់ផ្តើមបង្រៀនសិស្សមិនថានៅសាលារដ្ឋ ឬបង្រៀនក្រៅម៉ោងខ្ញុំតែងតែប្រាប់សិស្សពីភាពជោគជ័យនៃសិស្សជំនាន់មុនៗដល់សិស្សជំនាន់ក្រោយៗថាៈ ភាពជោគជ័យនេះបានមកពីកត្តាធំៗពីរជាចម្បងគឺ សិស្សខ្លួនឯង និង គ្រូ។

***កត្តារបស់សិស្ស**

ខ្ញុំប្រាប់ឲ្យសិស្សត្រូវតែគោរពវិន័យរបស់សាលាឲ្យបាននិងចាំបាច់ត្រូវតែមករៀនឲ្យបានទៀងទាត់ និងទាន់ពេលវេលាព្រោះការរៀនសូត្រដូចជាការឡើងកាំជណ្តើរដែរ បើមិនបានមករៀនមួយដងស្មើនឹងបាត់កាំជណ្តើរមួយកាំ បើឈប់ច្រើនឡើងដូចគេដកកាំជណ្តើរជាច្រើន។ ពេលដែលខ្ញុំចាប់ផ្តើមពន្យល់មេរៀន សិស្សទាំងអស់ត្រូវតែសមាធិប្រមូលអារម្មណ៍មិនត្រូវគិតពីនេះពីនោះទេ ហើយត្រូវតែប្រកាន់ខ្ជាប់នូវអង្គបួនដែលជាភាសាបាលី សុ ចិ បុ លិ អក្សរសង្ខេបពីពាក្យ សុត=ស្តាប់ ចិន្ត=គិត បុច្ឆ=សួរ លិខ=សរសេរ ឬ កត់ត្រា បើសិស្សណាដែលប្រកាន់បានទើបរៀនសូត្របានជោគជ័យ។ មិនតែប៉ុណ្ណោះសិស្សត្រូវធ្វើលំហាត់ឲ្យបានច្រើន និងស្រាវជ្រាវបន្ថែមទៀតតាមប្រព័ន្ធ **Internet** ដូចជា **YouTube** ឬ **Google** ហើយបើមានលំហាត់ណាមិនចេះត្រូវឆាប់សួរមិត្តភក្តិ ឬ លោកគ្រូអ្នកគ្រូពេលចប់ម៉ោង។

***កត្តារបស់គ្រូ**

ខ្ញុំត្រូវមានឆន្ទៈនិងមនសិការវិជ្ជាជីវៈជាគ្រូបង្រៀនមិនខ្លាចនឿយហត់ហើយមកបង្រៀនទៀងទាត់និងទាន់ពេលវេលា។មុនចាប់ផ្ដើមបង្រៀនមេរៀននីមួយៗ ខ្ញុំត្រូវរកគ្រប់វិធីសាស្ត្រដែលងាយយល់និងងាយស្ដាប់ ងាយចាំមិនងាយភ្លេចដើម្បីឲ្យសិស្សឆាប់ទទួលយកបាន ដោយដំបូងដាក់បញ្ហាឲ្យសិស្សដើម្បីឲ្យសិស្សរកវិធីដោះស្រាយ ពេលដែលសិស្សដោះស្រាយបានត្រឹមត្រូវហើយខ្ញុំដាក់ជាលំហាត់គំរូស្រាលៗតាមរូបមន្តងាយយល់ពីលំហាត់ងាយស្រួលទៅកម្រិតពិបាក។ ខ្ញុំតែងតែណែនាំវិធីសាស្ត្រងាយចាំ និយមន័យ ទ្រឹស្ដីបទ និងរូបមន្តផ្សេងៗ សម្រាប់យកទៅអនុវត្តក្នុងលំហាត់ ដូចជាសរសេររូបមន្តបិទក្នុងបន្ទប់រៀនផ្ទាល់ឬបិទកន្លែងណាដែលចេញចូលញឹកញាប់ហើយមានរូបមន្តខ្លះសរសេរជាកំណាព្យទៀត ឧទាហរណ៍ទម្រង់ឯកលក្ខណៈភាព តួមុខតួក្រោយលើកជាការ៉េ កណ្ដាលផលទ្វេគុណពីរតួ ក្រោយដកឬបូកយកតាមគួរ ការ៉េពីរតួដកឬបូកបញ្ជ្រាសត្រូវប្រឹងសម្លឹងឫស រកតួគន្លឹះត្រូវលៃលក តួមុខតួក្រោយត្រូវតែរក បើឃើញហើយយកបូកដកគ្នា។ ផលដកឬបូកនៃតួពីរ ដែលមាននាទីជាទ្វេធា ត្រូវលើកការ៉េបំពេញវា ទើបត្រឹមត្រូវជាទម្រង់ពិត។ ម៉្យាងទៀតខ្ញុំតែងតែណែនាំឲ្យសិស្សបែងចែកកាលវិភាគរៀននៅផ្ទះនិងប្រាប់ Website សម្រាប់ Download សៀវភៅលំហាត់បន្ថែមទៀត។ មិនតែប៉ុណ្ណោះខ្ញុំត្រូវតែស្រាវជ្រាវវិធីសាស្ត្រល្អពីមួយឆ្នាំទៅមួយឆ្នាំឲ្យកាន់តែល្អប្រសើរឡើងដោយមិនគិតនឿយហត់និងរិះរកគន្លឹះល្អៗដើម្បីឲ្យសិស្សរៀនឆាប់ចេះនិងស្រឡាញ់មុខវិជ្ជាគណិតដែលជាមុខវិជ្ជាសំខាន់សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រដទៃទៀត។

មានលំហាត់ខ្លះខ្ញុំអាចកាត់ក្រដាស់ដើម្បីបង្ហាញភាពជាក់ស្ដែងឲ្យសិស្សងាយយល់។ ខ្ញុំតែងតែណែនាំសិស្សដែលរៀនយឺតឲ្យបែងចែកក្រុមពិភាក្សាដែលក្នុងក្រុមនីមួយៗមានសិស្សរៀនពូកែជួយណែនាំបន្ថែមពេលទំនេរ។ ពេលប្រជុំក្រុមបច្ចេកទេសប្រចាំខែម្ដងៗខ្ញុំតែងតែចែករំលែកបទពិសោធន៍ និងលើកយកបញ្ហាខ្លះមកពិភាក្សាក្នុងក្រុមបច្ចេកទេសជៀសវាងការបង្រៀនសិស្សទាំងខុស។ ដោយសារតែកត្តាទាំងពីរធំៗខាងលើនេះហើយទើបធ្វើឲ្យសិស្សទទួលបានជោគជ័យ។

ជាចុងបញ្ចប់នេះខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងឲ្យកំណែទម្រង់ស៊ីជំរៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ទទួលបានលទ្ធផលល្អប្រសើរជាងនេះទៀត៕

## សេចក្ដីកែតម្រូវ

ក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ៤៦ មានកំហុសឆ្គងពាក្យ និងអក្ខរាវិរុទ្ធមួយចំនួន ។
សូមមិត្តអ្នកអានមេត្តាជួយកែតម្រូវៈ

| លរ | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|---|
| ១ | ១៦ | ២ | តែមានន័យប្រមាថ ។ល។ | តែមិនមានន័យប្រមាថ ។ល។ |
| ២ | ១៦ | ៣ | លោកអ្នកអាចដឹងហើយ | លោកអ្នកអាចខឹងហើយ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខៈ ០១៣/១៤ គ.ក

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ ឧសភា ឆ្នាំ២០១៤
## តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ
## សូមសំដែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើងនិងគ្រួសារ
## ហើយសូមចូលរួមរកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណៈភាពសមាជិក | | | | សពទី |
| 1. | ជុំ សាវឿន | ៤២ | ប | គ្រូមូលដ្ឋាន | អនុ.ទួលស្នុកី ស្រុកសំរោង ខេត្តកំពង់ស្ពឺ | 02-02-2014 | រោគាពាធ | 2180 កស្ព | 9601 |
| 2. | សូ បាន | ៦៨ | ប | គ្រូបឋម | ប.កណ្តាលជុំ(និវត្ត) ច្បារមន ខេត្តកំពង់ស្ពឺ | 06-01-2014 | រោគាពាធ | 1084 កស្ព | 9602 |
| 3. | ម៉ែន លឹម | ៦៩ | ប | គ្រូបឋម | ប.រលាំងបែង(និវត្ត) ថ្ពង ខេត្តកំពង់ស្ពឺ | 30-01-2014 | គាំងបេះដូង | 0986 កស្ព | 9603 |
| 4. | ណឹម នួន | ៦៧ | ប | គ្រូបឋម | ប.ពេជ្រនិល(និវត្ត) ភ្នំស្រួច ខេត្តកំពង់ស្ពឺ | 03-01-2014 | រោគាពាធ | 3719 កស្ព | 9604 |
| 5. | ជួប ចិន្តា | ៣៧ | ស | គ្រូមូលដ្ឋាន | អនុ.ជម្ពូព្រឹក្ស ឧដុង្គ ខេត្តកំពង់ស្ពឺ | 10-01-2014 | រោគាពាធ | 4493 កស្ព | 9605 |
| 6. | ឆឹង ស៊ីន | ៦៨ | ប | គ្រូបឋម | និវត្តជន. ប.ស្មើរជួល បរសេដ្ឋ ខេត្តកំពង់ស្ពឺ | 02-03-2014 | ទៀចទឹក | 2777 កស្ព | 9606 |
| 7. | ឃិន ស្មូធ | ៦៤ | ប | គ្រូបឋម | និវត្តជន. ប.ព្រៃត្បែង បរសេដ្ឋ ខេត្តកំពង់ស្ពឺ | 05-03-2014 | រោគាពាធ | 2879 កស្ព | 9607 |
| 8. | កែវ ស៊ីន | ៦៧ | ប | គ្រូបឋម | និវត្តជន. ស្រុកមេសហែក ខេត្តស្វាយរៀង | 23-02-2014 | របេងខួរឆ្អឹង | 1070 ស្វរ | 9608 |
| 9. | ទិត ស៊ីម | ៦៨ | ប | គ្រូបឋម | និវត្តជន. ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង | 13-03-2014 | មហារីកសួត | 3269 ស្វរ | 9609 |
| 10. | ម៉ូវ លន់ | ៧៣ | ប | គ្រូបឋម | និវត្តជន. មន្ទីរ អយក.ខេត្តស្វាយរៀង | 23-03-2014 | គ្រោះចរាចរ | 3639 ស្វរ | 9610 |
| 11. | មុី សាម៉ុល | ៦៣ | ប | គ្រូបឋម | និវត្តជន. ស្រុកស្វាយទាប ខេត្តស្វាយរៀង | 28-03-2013 | គ្រុនពោះ | 2327 ស្វរ | 9611 |
| 12. | ពី សុង | ៦០ | ប | គ្រូបឋម | និវត្តជន. ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង | 28-03-2014 | គ្រុនថ្លើម | 1624 ស្វរ | 9612 |
| 13. | មុិល ហ៊្វាន់ | ៦៤ | ស | គ្រូបឋម | និវត្តជន. ស្រុស្វាយជ្រុំ ខេត្តស្វាយរៀង | 30-03-2014 | លើសឈាម | 379 ស្វរ | 9613 |
| 14. | ស៊ិន សុផលា | ៤១ | ស | បឋម | បឋម វត្តលៀប ក្រុងបាត់ដំបង ខេត្តបាត់ដំបង | 07-02-2014 | រោគាពាធ | 5884 បប | 9614 |
| 15. | អ៊ុម ប្រឹម | ៧៤ | ប | បឋម | និវត្តជន. ស្រុកសង្កែ ខេត្តបាត់ដំបង | 11-02-2014 | រោគាពាធ | 2392 បប | 9615 |
| 16. | រស់ សាវុធ | ៧២ | ប | បឋម | និវត្តជន. ស្រុកបាណន់ ខេត្តបាត់ដំបង | 19-02-2014 | រោគាពាធ | 3648 បប | 9616 |
| 17. | គឹម សុជាត | ៦០ | ស | មបភ | និវត្តជន. ក្រុងបាត់ដំបង ខេត្តបាត់ដំបង | 22-02-2014 | រោគាពាធ | 590 បប | 9617 |
| 18. | លី វណ្ណា | ២៧ | ប | បឋម | បឋម ដូនត្រិត ស្រុកសំឡូត ខេត្តបាត់ដំបង | 26-02-2014 | មហារីកសួត | 11182 បប | 9618 |
| 19. | មែន សុខុម | ៨០ | ប | បឋម | និវត្តជន. ស្រុកសង្កែ ខេត្តបាត់ដំបង | 27-02-2014 | លើសឈាម | 5268 បប | 9619 |
| 20. | ហ៊ីង សុភា | ៥៦ | ប | បឋម | បឋម បឹងក្រសាល បាណន់ ខេត្តបាត់ដំបង | 15-03-2014 | រោគាពាធ | 9267 បប | 9620 |
| 21. | ហាច សាន | ៦៣ | ប | បឋម | និវត្តជន ស្រុកមោងឬស្សី ខេត្តបាត់ដំបង | 12-03-2014 | រោគាពាធ | 4120 បប | 9621 |
| 22. | អ៊ី ស៊ាន | ៧៧ | ប | គ្រូ | និវត្តជន. បឋមចំណោម ស្រុកមង្គលបូរី ប.មានជ័យ | 11-03-2014 | រោគាពាធ | 1071 បជ | 9622 |
| 23. | អ៊ា សាឡិត | ៦១ | ប | គបស | និវត្តជន. វិ.ទឹកជោរ ស្រុកព្រះនេត្រព្រះ បន្ទាយមានជ័យ | 04-03-2014 | មហារីកសួត | 1709 បជ | 9623 |
| 24. | វង ពេទ្យ | ៤៤ | ប | គ្រូបឋម | បម្រើការ បឋម.អង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | 19-03-2014 | រោគាពាធ | 5181 តក | 9624 |
| 25. | តាំ សុខឿន | ៤៣ | ប | គ្រូបឋម | បម្រើការ បឋម.ភ្នំខ្លែង ស្រុកទ្រាំង ខេត្តកែវ | 24-02-2014 | លើសឈាម | 642 តក | 9625 |
| 26. | កុក សុគន្ធ | ៦៤ | ប | គ្រូ | និវត្តជន ស្រុកអង្គបូរី ខេត្តតាកែវ | 02-03-2014 | រោគាពាធ | 3785 តក | 9626 |
| 27. | តៃ ជ | ៤០ | ប | គ្រូបឋម | បម្រើការ បឋម.ឆ្អាត់ ស្រុកបាទី ខេត្តតាកែវ | 12-03-2014 | រោគាពាធ | 5865 តក | 9627 |
| 28. | មុំ ង៉ឹម | ៧៨ | ប | គ្រូ | និវត្តជន ស្រុកទ្រាំង ខេត្តតាកែវ | 24-02-2014 | រោគាពាធ | 653 តក | 9628 |
| 29. | អ៊ឹង វណ្ណៈបុប្ផា | ៤៨ | ស | បឋម | បឋម ព្រៃក្រឡា ស្រុកបន្ទាយមាស ខេត្តកំពត | 16-02-2014 | រោគាពាធ | 3197 កព | 9629 |
| 30. | សូ សារិទ្ធ | ៦៥ | ប | គ្រូ | និវត្តជន បឋម ក្នុងខ្យង ស្រុកកំពង់ត្រាច ខេត្តកំពត | 04-03-2014 | រោគាពាធ | 1007 កព | 9630 |
| 31. | សែម ណុប | 69 | ប | គ្រូ | និវត្តជន បឋម មគ្គី វិសាលវន្ត ស្រុកដងទង់ ខេត្តកំពត | 04-03-2014 | រោគាពាធ | 2705 កព | 9631 |
| 32. | ប៊ុនចាន់សំណាង | ៣៦ | ប | បឋម | បឋម សាមគ្គីមានជ័យ ស្រុកអង្គជ័យ ខេត្តកំពត | 18-03-2014 | រោគាពាធ | 4844 កព | 9632 |
| 33. | ម៉ែន ចុន | ៦៩ | ប | គ្រូ | និវត្តជនបឋមត្រពាំងពោនស្រុកបន្ទាយមាស ខេត្តកំពត | 01-03-2014 | រោគាពាធ | 3171 កព | 9633 |
| 34. | ហម ឯក | ៣៨ | ប | បឋម | បឋម អង្គជុំ ស្រុកជុំគីរី ខេត្តកំពត | 22-03-2014 | គ្រោះចរាចរ | 4537 កព | 9634 |
| 35. | ជា មូល | ៥៥ | ប | បឋម | មជ្ឈមណ្ឌលកោសេយ្យ វប្បកម្មជាតិ ខេត្តសៀមរាប | 14-02-2014 | ក្អួតឈាម | 2914 សរ | 9635 |
| 36. | ថោង ប៉េងលី | ៧៥ | ប | គ្រូ | និវត្តជន បឋម ខ្លាឃ្មុំ ស្រុកជីក្រែង ខេត្តសៀមរាប | 03-03-2014 | ម.ពោះវៀន | 2374 សរ | 9636 |
| 37. | អ៊ិន វ៉ាន់នី | ៦០ | ប | គ្រូ | ការិយាល័យ អ.យ.កប្រាសាទបាគង ខេត្តសៀមរាប | 22-12-2013 | គាំងនោម | 1481 សរ | 9637 |
| 38. | សេក សាន | ៥៨ | ប | បឋម | បឋម ក្រវ៉ាន់ ស្រុកសៀមរាប ខេត្តសៀមរាប | 08-03-2014 | មហារីកថ្លើម | 7120 សរ | 9638 |
| 39. | ផេង សុងងន | ៤២ | ប | ម.ទ.ភ | វិទ្យាល័យដំដែក ខេត្តសៀមរាប | 09-03-2014 | លើសឈាម | 7833 សរ | 9639 |
| 40. | ម៉ន អិន | ៤៥ | ស | គ្រូបឋម | បឋម រមួល ស្រុកកំពង់សៀម ខេត្តកំពង់ចាម | 20-03-2014 | រោគាពាធ | 4643 កច | 9640 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 41. | កែវ ស៊ិន | ៧០ | ប | គ្រូបធ្យម | និវត្តជន វិ.ហស. ស្តន់ ជើងព្រៃ ខេត្តកំពង់ចាម | 13-03-2014 | ជរាពាធ | 260 កច | 9641 |
| 42. | កែវ បណ្ឌូល | ៥៦ | ប | គ្រូបឋម | បឋម ពព្រេង ស្រុកចំការលើ ខេត្តកំពង់ចាម | 21-03-2014 | លើសឈាម | 5746 កច | 9642 |
| 43. | ប៉ូច គឹមសេង | ៧៧ | ប | គ្រូបឋម | និវត្តជន. បឋម ប្រជាកុមារ ក្រុងសួង ខេត្តកំពង់ចាម | 29-03-2014 | ជរាពាធ | 9099 កច | 9643 |
| 44. | ស៊ុ ស៊ិន | ៦៨ | ប | គ្រូបឋម | និវត្តជន បឋមគរ ស្រុកព្រៃឈរ កំពង់ចាម | 12-02-2014 | ជរាពាធ | 3310 កច | 9644 |
| 45. | ហ៊ូ សុវណ្ណ | ៦១ | ប | គ្រូមធ្យម | និវត្តជន. វិ.ហស.ខ្ចៅ ស្រុកកងមាស ខេត្តកំពង់ចាម | 13-03-2014 | ជរាពាធ | 7220 កច | 9645 |
| 46. | ផេង ឈុនឡេង | ៥៥ | ប | គ្រូមធ្យម | វិ.បុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម | 24-03-2014 | លើសឈាម | 5868 កច | 9646 |
| 47. | សេង ប៊ុនឡាង | ៦៧ | ស | គ្រូបឋម | និវត្តជន បឋមម៉ែត្រ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម | 28-03-2014 | ជរាពាធ | 6362 កច | 9647 |
| 48. | ជា គឹមហៀង | ៥៥ | ស | គ្រូបឋម | បឋមភូមិបី រកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម | 05-04-2014 | ទឹក.ផ្អែម | 6479 កច | 9648 |
| 49. | កុល ឃីម | ៧៧ | ប | គ្រូបឋម | និវត្តជនវិ.ហេងសំរិនចក-ដំរីស ស្រុកអូរាំងឪ កំពង់ចាម | 21-03-2014 | ជរាពាធ | 1038 កច | 9649 |
| 50. | ហ៊ឹម ហួយ | ៧០ | ប | គ្រូបឋម | និវត្តជន បឋមដំណាក់ចារ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | 05-04-2014 | ជរាពាធ | 9303 កច | 9650 |
| 51. | ចន្ទ ស៊ីនួន | ៤២ | ប | មូលដ្ឋាន | វិ.ហស.កំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង | 02-03-2014 | ជរាពាធ | 6271 ពវ | 9651 |
| 52. | គង់ ផេង | ៧១ | ស | បឋម | និវត្តជន បឋមទួលព្រះធាតុ ស្រុកព្រះស្តេច ខេត្តព្រៃវែង | 22-02-2014 | ជរាពាធ | 629 ពវ | 9652 |
| 53. | មាស សុវណ្ណា | ៤៣ | ស | បឋម | បឋមសិរីសារពេជ្ជ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | 22-02-2014 | គាំងបេះដូង | 6918 ពវ | 9653 |
| 54. | អ៊ិន យ៉ាំង | ៧២ | ប | បឋម | និវត្តជន បឋមបុស្ស ស្រុកកំចាយមារ ខេត្តព្រៃវែង | 24-02-2014 | ជរាពាធ | 2514 ពវ | 9654 |
| 55. | ធួន ឈុនលី | ៤៩ | ប | បឋម | បឋមល្វា ស្រុកស្ទោង ខេត្តកំពង់ធំ | 20-01-2014 | ជរាពាធ | 2168 កធ | 9655 |
| 56. | អា សុថារ៉ា | ៤៨ | ស | បឋម | បឋមកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ | 24-02-2014 | ជរាពាធ | 2990 កធ | 9656 |
| 57. | វ៉ាន់ សាទ្រី | ៨១ | ប | បឋម | និវត្តជន មន្ទីអប់រំយុវជន និងកីឡាខេត្តកំពង់ធំ | 10-03-2014 | ជរាពាធ | 22 កធ | 9657 |
| 58. | ហ៊ាង ខុន | ៦១ | ប | គ្រូ | និវត្តជននា. រដ្ឋបាលការគ្រប់គ្រងគណៈ/ការកណ្តាល | 11-04-2014 | លើសឈាម | 080 គក | 9658 |
| 59. | ម៉េង លាង | ៧៩ | ប | គ្រូ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល | 28-03-2014 | ជរាពាធ | 2060 គក | 9659 |
| 60. | ស្វាយ សាវឿន | ៤១ | ស | បឋម | បឋម បឹងគ្រាំ ស្រុកល្វាឯម ខេត្តកណ្តាល | 21-02-2014 | គាំងបេះដូង | 7668 កណ | 9660 |
| 61. | អ៊ុំ កុសលវុឌ្ឍ | ៤១ | ប | ម.ទ.ភ | វិ.ហស.តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល | 10-03-2014 | ទឹក.ផ្អែម | 4088 កណ | 9661 |
| 62. | សឿន អឿន | ៤៤ | ស | ម.ប.ភ | អនុ.អនុវត្ត ក្រុងតាខ្មៅ ខេត្តកណ្តាល | 03-03-2014 | ជរាពាធ | 7948 កណ | 9662 |
| 63. | សយ សុខេន | ៤៣ | ប | ម.ប.ភ | អនុ.ឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល | 11-03-2014 | ជរាពាធ | 7675 កណ | 9663 |
| 64. | អ៊ឹង សុត | ៧៥ | ប | គ្រូ | និវត្តជន បឋមព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល | 15-03-2014 | ជរាពាធ | 438 កណ | 9664 |
| 65. | ឌុក លីវ | ៦៧ | ប | គ្រូ | និវត្តជន បឋម ឈូកក្រពុំ ស្រុកអង្គស្នួល ខេត្តកណ្តាល | 18-03-2014 | ជរាពាធ | 4940 កណ | 9665 |
| 66. | កែវ ថា | ៧៥ | ប | គ្រូ | និវត្តជន បឋមរនះ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | 18-03-2014 | ជរាពាធ | 12752 ភព | 9666 |
| 67. | សុក សោភ័ណ្ឌម្នី | ៤៥ | ស | ម.ទ.ភ | វិ.បាក់ទូក រាជធានីភ្នំពេញ | 31-03-2014 | ជរាពាធ | 1689 ភព | 9667 |
| 68. | ទូច ស៊ីសាថន | ៦៥ | ស | គ្រូ | និវត្តជន វិ.ជាស៊ីមសន្ធរម៉ុក រាជធានីភ្នំពេញ | 22-03-2014 | ជរាពាធ | 5821 ភព | 9668 |
| 69. | ង៉ែត រ៉ា | ៤៤ | ប | បឋម | បឋមវត្តបុទុមវតី ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 02-04-2014 | ជរាពាធ | 367 ភព | 9669 |
| 70. | ឯម មុន្នី | ៤៦ | ស | ម.ប.ភ | ការិ. អ.យ.ក ស្រុកបុទុមសាគរ ខេត្តកោះកុង | 27-03-2014 | គាំងបេះដូង | 253 កក | 9670 |

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ខ.មរណៈភាពគូស្រករ | | | | សពទី |
| 1. | អុប ចាន់ | ៤៥ | ប | កសិករ | ប្តីអ.សអ៊ឹងសុម៉ាយ៉ារី បឋមអង្គព្រះស្រីគងពិសីកំពង់ស្ពឺ | 23-01-2014 | ជរាពាធ | 0493 កស្ព | 5644 |
| 2. | អ៊ុក ស៊ីនឿន | ៥១ | ស | កសិករ | ប្រពន្ធល.សៅព្រំអង្គរ៉ាបឋមស្វាយធំស្វាយជ្រុំស្វាយរៀង | 09-02-2014 | រីកបេះដូង | 1769 ស្វរ | 5645 |
| 3. | ងួន ខេង | ៦៥ | ស | កសិករ | ប្រពន្ធល.ប៉ែន ណៃ និវត្តជន ក្រុងបាវិត ខេត្តស្វាយរៀង | 26-02-2014 | របេង | 5299 ស្វរ | 5646 |
| 4. | ទូច គីម | ៦០ | ស | កសិករ | ប្រពន្ធល.អ៊ី សារុនបឋម ហ.ស វាលខ្សាច ខេត្តស្វាយរៀង | 16-01-2014 | លើសឈាម | 4396 ពវ | 5647 |
| 5. | ឯម មាស | ៥២ | ប | កសិករ | ប្តីអ.សព្រំ សារ៉ាវី នៅការិ.អយក.ស្វាយទាបស្វាយរៀង | 28-03-2014 | ខ្យល់គរ | 2038 ស្វរ | 5648 |
| 6. | ធន់ សុមាលី | ៤៨ | ស | កសិករ | ប្រពន្ធល. ទិត វុទ្ធី បឋមជ្រៃធំ ស្រុករមាសហែក ស្វាយរៀង | 25-03-2014 | ទឹកនោមប្រៃ | 995 ស្វរ | 5649 |
| 7. | អ៊ុយ សាវឿន | ៥៦ | ប | កសិករ | ប្តី អ.ស ដឹប រ៉ាត អនុ.សំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង | 06-03-2014 | ម.គ្រាប់ឈាម | 4839 បប | 5650 |
| 8. | ឆាង អេង | ៦១ | ស | កសិករ | ភរិយាលោកអ៊ូច ម៉ៅ និវត្តជនមោងឬស្សី ខេត្តបាត់ដំបង | 28-02-2014 | ជរាពាធ | 4065 បប | 5651 |
| 9. | ធឹម ទូច | ៦៨ | ស | កសិករ | ភរិយាលោក សេង ត្រៃ និវត្តជន មោឬស្សី ខេត្តបាត់ដំបង | 17-03-2014 | ជរាពាធ | 3965 បប | 5652 |
| 10. | ប៉ែន លន់ | ៧៣ | ស | កសិករ | ភរិយាលោក ប៉ែន ផេង និវត្តជនស្រុកអង្គរបូរី ខេត្តតាកែវ | 27-02-2014 | ជរាពាធ | 3819 តក | 5653 |
| 11. | មាស ផន | ៧៣ | ស | កសិករ | ភរិយាលោក ប្រាក់ ហម ស្រុកគីរីវង់ ខេត្តតាកែវ | 25-02-2014 | ជរាពាធ | 4358 តក | 5654 |
| 12. | សាយ មួន | ៤៨ | ប | កសិករ | ប្តីអ.សទិត ផល្លីបឋមសិរីជោតវ៉ន ស្រុកបាទី ខេត្តតាកែវ | 10-03-2014 | ជម្ងឺខ្យល់គ | 1393 តក | 5655 |
| 13. | ទោះ សុផល | ៦០ | ស | កសិករ | ភរិយាល.ញ៉ូវ សុវណ្ណរតន៍និវត្តជនកោះអណ្តែត តាកែវ | 05-01-2014 | ជរាពាធ | 2080 តក | 5656 |
| 14. | ព្រហ្ម សារិន | ៤៥ | ស | កសិករ | ភរិយាល.ទុយ សុងបឋមកំហាល់ស្រុកអង្គរបូរី ខេត្តតាកែវ | 24-03-2014 | ជរាពាធ | 3702 តក | 5657 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 15. | ខាត់ ប៊ុន្នី | ៤៦ | ប | មេភូមិ | ប្តី អស.កៅ ភីណាបឋមថ្មគោល កំពង់សៀម កំពង់ចាម | 11-03-2014 | ជម្ងឺសួត | 4320 កច | 5658 |
| 16. | ស៊ឹម ទុន | ៣៤ | ស | កសិករ | ភរិយា.ល.ហម.យិត.អនុ.កំពង់ឬស្សី ពោធិ៍រៀង ព្រៃវែង | 24-01-2014 | ជរាគាពាធ | 11279 ពវ | 5659 |
| 17. | កែវ យឿន | ៦៥ | ស | កសិករ | ភរិយា.ល.ឈឹម លាង.និវត្តជនបឋមធ្លក បាភ្នំ ព្រៃវែង | 28-02-2014 | ជរាគាពាធ | 4277 ពវ | 5660 |
| 18. | ពេញ នី | ៤២ | ស | មេផ្ទះ | ភរិយា.ល.លាង ផល្លាបឋមអង្គទ្រេតស្វាយអន្ទរ ព្រៃវែង | 18-02-2014 | ជរាគាពាធ | 3984 ពវ | 5661 |
| 19. | ជុន វិចាន់ | ៤៨ | ប | កសិករ | ស្វាមី.លស.យូ បានបឋមឯករាជ្យកំពង់ត្របែក ព្រៃវែង | 02-02-2014 | គ្រោះចរាចរ | 1898 ពវ | 5662 |
| 20. | មាស សាផឿន | ៧៥ | ស | មេផ្ទះ | ភរិយា.ល.តាំងឡុងនិវត្តជនបឋមអម្ពិលកំ.ត្របែក ព្រៃវែង | 03-03-2014 | ជរាពាធ | 7334 ពវ | 5663 |
| 21. | ឡុង ប៉ានី | ៦៦ | ស | កសិករ | ភរិយា.ល.យិន សួរ និវត្តជនបឋមព្រៃមាន់ពាមជរ ព្រៃវែង | 17-02-2014 | ជរាគាពាធ | 3236 ពវ | 5664 |
| 22. | មាស សូត្រ | ៦៤ | ស | កសិករ | ភរិយា.ល.ទេពស៊ីននិវត្តជនអនុ.ដំរីពួនស្វាយអន្ទរព្រៃវែង | 15-03-2014 | ជរាគាពាធ | 3764 ពវ | 5665 |
| 23. | សុខ ចំរើន | ៦៤ | ប | កសិករ | ស្វាមី មាសសាលាងនិ.បឋមព្រៃពោនកំ.ត្របែក ព្រៃវែង | 18-03-2014 | ជរាគាពាធ | 1551 ពវ | 5666 |
| 24. | ធួន ឈុនលី | ៤៩ | ប | បឋម | ប្តីអ.សសឹង វាសនា បឋមកំពង់ចិន ស្ទោង ខេត្តកំពង់ធំ | 20-01-2014 | ជរាគាពាធ | 1961 កធ | 5667 |
| 25. | លឹម វួចជា | ៥៩ | ស | មេផ្ទះ | ប្រពន្ធល.ឈុន យាន និ.អយក.ស្ទោង ខេត្តកំពង់ធំ | 04-02-2014 | ជរាគាពាធ | 2273 កធ | 5668 |
| 26. | កុយ ស៊ីថូ | ៦៥ | ស | មេផ្ទះ | ប្រពន្ធល.នួន ស៊ន និ.អយក.ស្រុកស្ទោង ខេត្តកំពង់ធំ | 31-01-2014 | ជរាគាពាធ | 2092 កធ | 5669 |
| 27. | ខឹម គឹមយន | ៦៦ | ស | មេផ្ទះ | ប្រពន្ធវ័ត្តហួរនិវត្តជនបឋមត្រពាំងជ្រៃបារាយណ៍ កំពង់ធំ | 27-02-2014 | ជរាគាពាធ | 1014 កធ | 5670 |
| 28. | ស៊ឹម ណៃម | ៧៤ | ស | មេផ្ទះ | ប្រពន្ធល.ឆាយ ហមនិវត្តជនបឋមខ្នារក្រុងខេត្តសៀមរាប | 25-11-2013 | លើសឈាម | 846 សរ | 5671 |
| 29. | អ៊ឹង ញ៉ | ៦២ | ស | មេផ្ទះ | ប្រពន្ធល.ថោង សុផលនិ. ការគ្រ.គណៈក/ការកណ្តាល | 07-03-2014 | ជរាគាពាធ | 4499 គក | 5672 |
| 30. | អ៊ុក វង់ | ៦៩ | ប | កសិករ | ប្តីល.ជូ កេងលី បឋមគគីរ កៀនស្វាយ ខេត្តកណ្តាល | 15-02-2014 | ជរាគាពាធ | 7053 កណ | 5673 |
| 31. | ស្វាយ សាផឿន | ៤១ | ស | បឋម | ប្រពន្ធលោក រស់ ស្លូតបឋមបឹងគ្រំ ល្វាឯម ខេត្តកណ្តាល | 21-02-2014 | គាំងបេះដូង | 2704 កណ | 5674 |
| 32. | ម៉ែន ញ៉ៀន | ៦៩ | ស | មេផ្ទះ | ប្រពន្ធល.អ៊ូ ហ៊ីម និ.បឋមកោះសុក្រំ ក.ស្អឹង កណ្តាល | 24-06-2014 | លើសឈាម | 4441 កណ | 5675 |
| 33. | ប៉ែន ពិសិដ្ឋ | ៣២ | ប | ស្ថាបនា | ប្តីអ.សចែមស្រីអូន អនុ.ជើងកើបកណ្តាលស្អឹង កណ្តាល | 14-03-2014 | គ្រោះចរាចរ | 11633 កណ | 5676 |
| 34. | ឆាយ សាំងគាវ | ៥៨ | ស | មេផ្ទះ | ប្រពន្ធល.ងក សុគ្រីបឋមស្វាយតានី ស្អាង កណ្តាល | 01-03-2014 | ជរាគាពាធ | 5779 កណ | 5677 |
| 35. | ហេង អូន | ៤៧ | ប | លក់ដូរ | ប្តីអ្នកគ្រូ អ៊ុល សុផារ៉ា វិ.ទួលទំពូង រាជធានីភ្នំពេញ | 06-03-2014 | លើសឈាម | 7532 ភព | 5678 |

មេត្តាប្រមូលភាគទានឧបត្ថម្ភប្រចាំខែ ឧសភា ឆ្នាំ២០១៤ ឱ្យទាន់ពេលវេលាដើម្បីដោះស្រាយជូនគ្រួសារសព។

| | | |
|---|---|---|
| ចំណាំ: ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក | : ៧០ ន × ៤០ | : ២៨០០៛ |
| សពគ្រួសារ | : ៣៥ ន × ២០ | : ៧០០៛ |
| ភាគទានប្រចាំខែ | | : ២០០៛ |
| ភាគទានសាងសង់ផ្ទះគ្រូបង្រៀន | | : ៣០០៛ |
| សរុប | | : ៤.០០០៛ |

រាជធានីភ្នំពេញ, ថ្ងៃទី០៥ខែ ឧសភា ឆ្នាំ២០១៤

ជ.គណៈកម្មាធិការកណ្តាល

អគ្គលេខាធិការរង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមបុគ្គលិកសិក្សាខ្មែរ**

**គណៈកម្មាធិការកណ្តាល**

លេខ: ១៥/១៤ គ.ក

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ មិថុនា ឆ្នាំ២០១៤

## តារាងសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ

## សូមសំដែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតមិត្តយើង និងគ្រួសារ

## ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខណ្ឌ | អង្គភាពបំពីការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| ក.មរណៈភាពសមាជិក | | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ហេង ហេន | ៧៤ | ប | កម្មករ | និវត្តជនការិ.រដ្ឋបាល-មន្ទីរ អយក.ខេត្តកំពង់ចាម | ២០.០៤.១៤ | រោគាពាធ | ២.៦៥៤ កច | ៩៦៧១ |
| ២ | ឡុច ស៊ីធន់ | ៤៤ | ប | គ្រូមធ្យម | អនុវិ.បឹងកុក -ក្រុង កំពង់ចាម - កំពង់ចាម | ១៨.០៤.១៤ | គ្រោះចរាចរ | ១៧៨.កច | ៩៦៧២ |
| ៣ | សំ ឈន | ៤២ | ប | គ្រូបឋម | បឋម សូគង - កងមាស - កំពង់ចាម | ២៣.០៤១៤ | ក្រិនថ្លើម | ៨២៩១.កច | ៩៦៧៣ |
| ៤ | ហួត ស៊ីទិត | ៧៧ | ប | គ្រូបឋម | និវត្តជន ការិ.អយក.ស្រុក-កោះសូទិន-កំពង់ចាម | ០១.០៤.១៤ | រោគាពាធ | ៤៧៩៩ កច | ៩៦៧៤ |
| ៥ | យក់ រុន | ៦៩ | ស | គ្រូបឋម | និវត្តជន ការិបឋមល្វេ-កោះសូទិន-កំពង់ចាម | ១៦.០៤.១៤ | រោគាពាធ | ៤៧៧៥ កច | ៩៦៧៥ |
| ៦ | ជឹម ចាន់ធឿន | ៤២ | ប | គ្រូបឋម | បឋម ប៉ាក់ណាម - កោះសូទិន - កំពង់ចាម | ១៩.០៤.១៤ | រោគាពាធ | ៤៧១០ កច | ៩៦៧៦ |
| ៧ | ស៊ិន ស៊ីថន | ៦៧ | ប | គ្រូបឋម | និវត្តជន បឋមត្រពាំងកក់- ជើងព្រៃ- កំពង់ចាម | ២០.០៤.១៤ | រោគាពាធ | ២.៥០៥ កច | ៩៦៧៧ |
| ៨ | ហ៊ូ សំអោក | ៧៣ | ប | គ្រូបឋម | និវត្តជន បឋមដូនេ្ដា - ជើងព្រៃ - កំពង់ចាម | ០៩.០៤.១៤ | រោគាពាធ | ២.៤៥៥ កច | ៩៦៧៨ |
| ៩ | ហាក់ យីន | ៧២ | ប | គ្រូបឋម | និវត្តជន បឋមព្រៃទទឹង -ព្រៃឈរ- កំពង់ចាម | ០៨.០៤.១៤ | រោគាពាធ | ៣៤៩១ កច | ៩៦៧៩ |
| ១០ | សុក ប៊ុនណា | ៦០ | ប | គ្រូមធ្យម | វិ.ហស.ព្រៃទទឹង-ព្រៃឈរ- កំពង់ចាម | ១៧.០៣.១៤ | រោគាពាធ | ២៧៨៤ កច | ៩៦៨០ |
| ១១ | ជួប ស៊ាង | ៦៧ | ប | គ្រូបឋម | និវត្តជន បឋមជុបកើត-ក្រុងសួង- កំពង់ចាម | ១៨.០៥.១៤ | រោគាពាធ | ៩៨៥០ កច | ៩៦៨១ |
| ១២ | រស់ សំអឿន | ៤៣ | ប | គ្រូមធ្យម | ការិ.អ.យ.ក.ស្រុក-ស្រីសន្ធរ- កំពង់ចាម | ០៧.០៤.១៤ | រោគាពាធ | ៧០៦០ កច | ៩៦៨២ |
| ១៣ | វ៉ា ជុំ | ៧៤ | ប | គ្រូបឋម | និវត្តជន ស្រុកស្វាយទាប ខេត្តស្វាយរៀង | ១៦.០៤.១៤ | លើសឈាម | ៥០០២ ស្វរ | ៩៦៨៣ |
| ១៤ | អ៊ុក តង់ | ៧១ | ប | គ្រូបឋម | និវត្តជន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង | ២២.០៤.១៤ | របេង | ២៦៥៩ ស្វរ | ៩៦៨៤ |
| ១៥ | នូរ ទិត្យ៉ារ៉ា | ៤៥ | ប | គ្រូបឋម | បឋមម៉ឺនជ័យ ស្រុករំដួល ខេត្តស្វាយរៀង | ២២.០២.១៤ | រោគាពាធ | ២៨៣០ ស្វរ | ៩៦៨៥ |
| ១៦ | ម៉ៅ ញឹប | ៧៨ | ប | គ្រូបឋម | និវត្តជន ស្រុករមាសហែក ខេត្តស្វាយរៀង | ០៣.០៥.១៤ | ជរាពាធ | ១២៩៧ ស្វរ | ៩៦៨៦ |
| ១៧ | រស់ គឹមហួត | ៤៤ | ស | គ្រូបឋម | វិ. ប៊ុនរ៉ានី ហ៊ុន សែន រលាប្អៀរ ខេត្តកំពង់ឆ្នាំង | ១៩.០២.១៤ | មហារីកដោះ | ០២៣៦៦ កឆ | ៩៦៨៧ |
| ១៨ | ប៉ាត សុទ្ធី | ៥៧ | ប | គ្រូបឋម | បឋម ព្រះឥន្ទទេព ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង | ០៨.០៣.១៤ | ក្រិនថ្លើម | ២៦៥៩ កឆ | ៩៦៨៨ |
| ១៩ | ហែម សុទ្ធា | ៤១ | ប | គ្រូមធ្យម | វិ.ហ៊ុន សែន បិរបូណ៌ ខេត្តកំពង់ឆ្នាំង | ០២.០៣១៤ | ក្រិនថ្លើម | ០២០៤២ កឆ | ៩៦៨៩ |
| ២០ | នួន ថាវី | ៥១ | ប | គ្រូបឋម | បឋម គ្រួស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ១៥.០៣.១៤ | របេង | ០២៣៩៤ កឆ | ៩៦៩០ |
| ២១ | តឹក GuIន | ២៧ | ស | គ្រូមធ្យម | វិ.ប.ហស រលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២៧.០១.១៤ | បេះដូងរីក | ០៤១៨៣ កឆ | ៩៦៩១ |
| ២២ | សួង ភារិទ្ធ | ៤៤ | ប | គ្រូមធ្យម | វិ.ព្រះបាទសុរាម្រឹត ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | ០៧.០២.១៤ | ក្រិនថ្លើម | ០១៥០២ កឆ | ៩៦៩២ |
| ២៣ | ព្រុំ ឈា | ៥៨ | ប | គ្រូបឋម | បឋម.សំព័រ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ១០.០២.១៤ | ជម្ងឺថ្លើម | ០១០៩២ កឆ | ៩៦៩៣ |
| ២៤ | ទូច ឈុនអេង | ៦១ | ស | បឋម | និវត្តជន ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ | ១៥.០៤.១៤ | រោគាពាធ | ០៧៤៧ ក្រច | ៩៦៩៤ |
| ២៥ | វៀង យ៉េស | ៦៣ | ប | បឋម | និវត្តជន ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ | ១០.០៤.១៤ | រោគាពាធ | ១០៩៨ ក្រច | ៩៦៩៥ |
| ២៦ | ម៉ាន ឧស្មាន | ៧០ | ប | បឋម | និវត្តជន ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ | ០៧.០៤១៤ | រោគាពាធ | ១៣៩៩ ក្រច | ៩៦៩៦ |
| ២៧ | ស្វាយ រាជ | ៦៨ | ប | គ្រូមធ្យម | និវត្តជន អ.វិ សីហនុ ស្រុកក្រគរ ខេត្តពោធិ៍សាត់ | ៣០.១២.១៣ | គ្រួសក្នុងប្រម៉ាត់ | ១៧៣៣ ពស | ៩៦៩៧ |
| ២៨ | ថ្លាង ប៊ិច | ៦៩ | ប | គ្រូបឋម | និវត្តជនបឋមស្រះម្កាក់ ស្រុកបាកាន ខេត្តពោធិ៍សាត់ | ០៥.០៣.១៤ | រលាក់សួត | ២១៨៩ ពស | ៩៦៩៨ |
| ២៩ | ស៊ីម ធៀង | ៤៦ | ប | គ្រូមធ្យម | បង្រៀននៅសាលាគរុកោសល្យ ខេត្តពោធិ៍សាត់ | ២៥.០១.១៤ | ក្រិនថ្លើម | ១៣៥៨ ពស | ៩៦៩៩ |
| ៣០ | ថ្លាង ផង់ | ៦៨ | ប | គ្រូបឋម | និវត្តជនស្រុកបាកានខេត្តពោធិ៍សាត់ | ២៩.០១.១៤ | ទឹកនោមប្រៃ | ១១៧០ ពស | ៩៧០០ |
| ៣១ | ពៅ វាសនា | ៤៥ | ប | គ្រូបឋម | បង្រៀននៅសាលាបឋមភ្នំទ្រព្យ ខេត្តពោធិ៍សាត់ | ១៥.១២.១៣ | គាំងបេះដូង | ៦០៣ ពស | ៩៧០១ |
| ៣២ | ខោល ស៊ីផាន | ៥៩ | ប | គ្រូបឋម | បង្រៀននៅបឋមក្រាំងវែង ស្រុកក្រគរ ខេត្តពោធិ៍សាត់ | ០៧.០២.១៤ | គាំងបេះដូង | ១៦៦៩ ពស | ៩៧០២ |
| ៣៣ | យាន វណ្ណា | ៤០ | ប | គ្រូបឋម | បង្រៀននៅបឋមឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ | ១៨.០២.១៤ | ខ្យល់គរ | ១៧៩១ ពស | ៩៧០៣ |
| ៣៤ | ប៉ាល់ មាន | ៦៦ | ប | គ្រូបឋម | និវត្តជនការិអយកស្រុកបាកានខេត្តពោធិ៍សាត់ | ២៥.០២.១៤ | ក្រិនសរសៃ | ១៨៣៩ ពស | ៩៧០៤ |
| ៣៥ | អ៊ុន សារី | ២៦ | ប | គ្រូមធ្យម | បង្រៀននៅវិអុរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ | ២៦.០៤.១៤ | ខូចតម្រងនោម | ៤៥៤៩ ពស | ៩៧០៥ |
| ៣៦ | ផឹង ជាម | ៦៩ | ប | គ្រូ | និវត្តជន ស្រុកសំរោង ខេត្តតាកែវ | ២៧.០៣.១៤ | រោគាពាធ | ៣៥៥៦ តក | ៩៧០៦ |
| ៣៧ | សែម យេន | ៦៩ | ប | គ្រូ | និវត្តជន ស្រុកគីរីវង់ ខេត្តតាកែវ | ១៣.០៤.១៤ | រោគាពាធ | ៤៤៥៨ តក | ៩៧០៧ |
| ៣៨ | ខៀវ សារ៉ន | ៦៩ | ប | គ្រូ | និវត្តជន ក្រុងដូនកែវ ខេត្តតាកែវ | ២៣.០៣.១៤ | រោគាពាធ | ៣៦០០ តក | ៩៧០៨ |
| ៣៩ | ខឹម ឈុន | ៨៥ | ប | គ្រូ | និវត្តជន ស្រុកទ្រាំង ខេត្តតាកែវ | ០៨.០៤.១៤ | លើសឈាម | ១៩៩៩ តក | ៩៧០៩ |
| ៤០ | អ៊ឹង ជី | ៤៥ | ប | គ្រូបឋម | បឋម -ស.ហ-បានយ.ស-ព្រែកប្បាស. តាកែវ | ១៧.០៤.១៤ | រោគាពាធ | ៥១៧៤ តក | ៩៧១០ |
| ៤១ | សុខ ឡេង | ៦១ | ប | គ្រូ | និវត្តស្រុកសំរោង ខេត្តតាកែវ | ០២.០៥.១៤ | រោគាពាធ | ៣០០៣ តក | ៩៧១១ |
| ៤២ | ឃឹម បូរាណ | ៤០ | ប | ម.បក | អនុវិទ្យាល័យទៀន ម.អ.យក រាជធានីភ្នំពេញ | ២៨.០៣.១៤ | មហារីកច្រមុះ | ១២៨៣៨ ភព | ៩៧១២ |
| ៤៣ | ឡាយ ចំរើន | ៤៦ | ប | គ្រូបឋម | បឋម.អង្គស្នួក ខ័ណ្ឌពោធិ៍សែនជ័យ ភ្នំពេញ | ៣១.០៣.១៤ | គាំងបេះដូង | ១២៤២៥ ភព | ៩៧១៣ |
| ៤៤ | សរ ធីតា | ៤៧ | ស | ម.ប.ភ | អនុ.វិ ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ | ១៩.០៣.១៤ | រោគាពាធ | ៣៤៤២ ភព | ៩៧១៤ |
| ៤៥ | ភុន រិន | ៧៧ | ប | គ្រូ | និវត្តជន.បឋម.សៃសិន ក្រុងសិរីសោភ័ណ បន្ទាយមានជ័យ | ២៥.០៤.១៤ | ទឹកនោមផ្អែម | ៣២៩០ បជ | ៩៧១៥ |
| ៤៦ | ខឹម កាណុល | ៥៩ | ប | ម.ប.ភ | មន្ទីរអប់រំយុវជន និងកីឡា ខេត្តព្រះសីហនុ | ០៧.០៣.១៤ | រោគាពាធ | ២៥៩ ស.ន | ៩៧១៦ |
| ៤៧ | ស្រី ស៊ីណាត | ៤៩ | ប | បឋម | ការិយាល័យអប់រំយុវជន និងកីឡាស្រុកអង្គរជ័យ ខេត្ត កំពត | ០៨.០៣.១៤ | រោគាពាធ | ១២៨៨ កព | ៩៧១៧ |
| ៤៨ | ទេព សេដ្ឋា | ៦៤ | ប | គ្រូ | និវត្តជន បឋមក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត | ០៧.០២.១៤ | រោគាពាធ | ២៤០៧ កព | ៩៧១៨ |
| ៤៩ | ឈុន ថូ | ៦៨ | ប | បឋម | បឋមសិក្សាតាអី ស្រុកប្រាសាទបាគង ខេត្តសៀបរាម | ២៥.០២.១៤ | រោគាពាធ | ១៦៣០ សរ | ៩៧១៩ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥០ | ប៉ាង បឿ | ៤០ | ប | បឋម | បឋម ពេជ្រម្តុង ស្រុកល្វាឯម ខេត្តកណ្តាល | ២៥.០៣.១៤ | រលាកថ្លើម | ៧៥៤៨ កណ | ៩៧២០ |
| ៥១ | ស៊ឹម សុវណ្ណារី | ៤៤ | ស | បឋម | បឋម បារ៉ែនលើ ស្រុកស្អាង ខេត្តកណ្តាល | ២៩.០៣.១៤ | ជរាពាធ | ៦០៤២ កណ | ៩៧២១ |
| ៥២ | ជឹម ហ៊ន | ៦០ | ប | ម.ប.ភ | វិ.ហ-សកោះចិន ស្រុកពញាឮ ខេត្តកណ្តាល | ២៦.០៣.១៤ | ជរាពាធ | ១៤៨៧ កណ | ៩៧២២ |
| ៥៣ | ងួន កុល | ៦១ | ប | បឋម | បឋម មណ្ឌល អភិវឌ្ឍន៍ស្រែអំពិល ស្រុកកៀនស្វាយ | ២៩.០៣.១៤ | កាំងបេះដូង | ៧៧៦៩ កណ | ៩៧២៣ |
| ៥៤ | អិន ថា | ៥៧ | ប | បឋម | បឋម សំរោង ស្រុកកៀនស្វាយ ខេត្តកណ្តាល | ០៥.០៤.១៤ | គ្រោះចរាចរ | ៧២៧៥ កណ | ៩៧២៤ |
| ៥៥ | សៅ កុសល | ៦៨ | ប | បឋម | បឋម បន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល | ១២.០៤.១៤ | ជរាពាធ | ៧២០២ កណ | ៩៧២៥ |
| ៥៦ | ស្រី សារឿន | ៧២ | ស | គ្រូ | និវត្តជន បឋម សុធារស គ្រប់គ្រងគណៈកម្មាធិការ- កណ | ២១.០២.១៤ | ជរាពាធ | ៤៥៣៣ ក.ក | ៩៧២៦ |
| ៥៧ | គង់ ណាន | ៦៧ | ប | គ្រូ | និវត្តជន នា.បណ្តុះបណ្តាល និងក្រិតការគណៈ/ការកណ | ០៥.០៥.១៤ | ទឹកនោមផ្អែម | ៤៨៧ គ.ក | ៩៧២៧ |
| ៥៨ | ហុក សំអឿន | ៧១ | ប | គ្រូ | និវត្តជន មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា -គណៈ/ការកណ | ០៨.០៥.១៤ | ជរាពាធ | ២២០៣ គ.ក | ៩៧២៨ |
| ៥៩ | យិន គុំ | ៧០ | ប | បឋម | និវត្តជន ស្រុករតនមណ្ឌល ខេត្តបាត់ដំបង | ១១.០៣.១៤ | ជរាពាធ | ១៩៣៨ បប | ៩៧២៩ |
| ៦០ | អឿ សារ៉ាន់ | ៦៩ | ប | បឋម | និវត្តជន ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ០៨.០៤.១៤ | លើសឈាម | ៤៦៥៦ បប | ៩៧៣០ |
| ៦១ | សុខ សេង | ៨៤ | ប | បឋម | និវត្តជន ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ១៨.០៤.១៤ | ជរាពាធ | ២៨២៩ បប | ៩៧៣១ |
| ៦២ | កែម ង៉ា | ៦៩ | ប | បឋម | និវត្តជន ស្រុកបវេណ ខេត្តបាត់ដំបង | ២០.០៤.១៤ | ជរាពាធ | ២៩៩៤ បប | ៩៧៣២ |
| ៦៣ | ស លៀង | ៧១ | ស | បឋម | និវត្តជនមន្ទីរអប់រំយុវជននិងកីឡាខេត្តបាត់ដំបង | ២២.០៤.១៤ | ជរាពាធ | ០២១ បប | ៩៧៣៣ |
| ៦៤ | វណ្ណ នឿម | ៧៥ | ស | បឋម | និវត្តជនមន្ទីរអប់រំយុវជននិងកីឡាខេត្តបាត់ដំបង | ២៥.០៤.១៤ | គាំងបេះដូង | ០៩០ បប | ៩៧៣៤ |
| ៦៥ | សិត មៅ | ៣១ | ប | បឋម | បឋម សុវណ្ណគីរី ស្រុកសំឡូត ខេត្តបាត់ដំបង | ២១.០៤.១៤ | ខាន់ស្លាក់ | ១០៤០៤ បប | ៩៧៣៥ |
| ៦៦ | អិត កៀន | ៦៨ | ប | បឋម | និវត្តជន ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ២៥.០៤.១៤ | ជរាពាធ | ១២០៧ បប | ៩៧៣៦ |
| ៦៧ | ជា សុខា | ២៤ | ប | មទភ | វិ.ជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង | ០១.០៥.១៤ | គ្រោះចរាចរ | ១១៩៦៥ បប | ៩៧៣៧ |
| ៦៨ | ធាន ថាន់សឺន | ៥៤ | ប | បឋម | បឋមអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង | ០៤.០៥.១៤ | ជម្ងឺ | ១៧៩៩ បប | ៩៧៣៨ |
| ៦៩ | សួង វ៉ាត់ | ៨៦ | ប | បឋម | និវត្តចន ក្រុងបាត់ដំបង ខេត្តបាត់ដំបង | ០៧.០៥.១៤ | ជរាពាធ | ២៨៤១ បប | ៩៧៣៩ |
| ៧០ | ខៀវ ហៀវ | ៧៧ | ប | បឋម | និវត្តជន ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ០៨.០៥.១៤ | លើសឈាម | ៤៣១៦ បប | ៩៧៤០ |

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ខ.មរណៈភាពគូស្រករ | | | | |
| ១ | ជឹម ចាន់ធឿន | ៤២ | ប | គ្រូមធ្យម | ប្តីអស.កាំង សេងសុគន្ធីវិ.ជីហែរកោះសូទិនកំពង់ចាម | ១៩.០៤.១៤ | ជរាពាធ | ១៨២៣ កច | ៥៦៧៩ |
| ២ | ម៉ម ឡេម | ៦៩ | ស | កសិករ | ប្រពន្ធលោក ស្រង់ ឡូ បឋមពញ្រែង-ចំការលើ កំពង់ចាម | ០១.០៥.១៤ | ជរាពាធ | ៥៧៧១ កច | ៥៦៨០ |
| ៣ | សុខ ឈឿន | ៥៦ | ប | កសិករ | ប្តីអសសុខសុមន្តនបឋមថ្មគោលកំពង់សៀមកំពង់ចាម | ០៣.០៥.១៤ | មហារីកបំពង់ករ | ៤៣១៣ កច | ៥៦៨១ |
| ៤ | សំ ឈន | ៤២ | ប | គ្រូបឋម | ប្តីអសរៀម ផេងលីមបឋមកោះតាង៉ោ-កងមាសកំពង់ចាម | ២៣.០៤.១៤ | ក្រិនថ្លើម | ៨៤០៤ កច | ៥៦៨២ |
| ៥ | ផេង វ៉ា | ៤៦ | ប | កសិករ | ប្តីអស.ង៉ែ ចាន់ថុល អនុវិ.ខ្វិតធំ-ព្រៃឈរ -កំពង់ចាម | ២៦.០៣.១៤ | គ្រោះចរាចរ | ២៨៩១ កច | ៥៦៨៣ |
| ៦ | អិន ណាត | ៦៧ | ស | កសិករ | ប្រពន្ធលោកហាក់ យឺនបឋមព្រៃទទឹងព្រៃឈរកំពង់ចាម | ០៣.០៤.១៤ | ជរាពាធ | ៣៤៩១ កច | ៥៦៨៤ |
| ៧ | កែម សឿន | ៥៤ | ស | កសិករ | ប្រពន្ធល.ភួង បឿនបឋមប្រឹមប្រីយ៍-ព្រៃឈរ-កំពង់ចាម | ០៩.០៤.១៤ | លើសឈាម | ២៧៤០ កច | ៥៦៨៥ |
